ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
## និងច្បាប់ស្តីពីវិសោធនកម្មច្បាប់
## ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

# ព្រះរាជក្រម

នស_រកម_១២៩៧_០៦

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

::::::::::::

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត_១០៩៤_៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស_រកត_០៨៩៧_១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស.រកម_០១៩៦_០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស.រកម_១១៩៧_០៧ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីគណៈបក្សនយោបាយ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រី ទី២ និងអំពី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ព្រះរាជក្រម

នស/រកម/០៩០២/០១៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យអត្ថបទច្បាប់នេះ ឱ្យទាន់តាមកាលកំណត់របស់មាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤៧/០០២/២០០២ កបធ.ច ចុះថ្ងៃទី ០៦ កញ្ញា ឆ្នាំ ២០០២ ។

ច្បាប់នេះមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ព្រះរាជក្រម

នស/រកម/០៦០៦/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់យល់ស្របលើទម្រង់ និងគតិច្បាប់ព្រមទាំងលើខ្លឹមសារនៃអត្ថបទច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែ កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី ២ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមរយៈសេចក្តីសម្រេចលេខ ០៧៩/០០៦/ ២០០៦ កបធ.ច ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

នស/រកម/០១០៧/០០៦

# ព្រះរាជក្រម

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ហើយក្រុមប្រឹក្សា-ធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមរយៈសេចក្តីសម្រេចលេខ ០៩១/០០២/២០០៧ កបធ.ប ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ព្រះរាជក្រម

នស/រកម/០៧១១/០១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១៦/០០៥/២០១១ កបធ.ច ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# វិសោធនកម្មច្បាប់ស្តីពី
# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រាមួយ.-**

ត្រូវបានកែប្រែមាត្រា ១០៩ មាត្រា ១៣១ និងមាត្រា ១៣៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ មាត្រា ៣២ថ្មី មាត្រា ៥៤ថ្មី មាត្រា ៥៦ថ្មី មាត្រា ៥៩ថ្មី មាត្រា ៦១ថ្មី មាត្រា ៦២ថ្មី មាត្រា ៦៤ថ្មី មាត្រា ៦៥ថ្មី មាត្រា ៦៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ និងមាត្រា ៤៩ ថ្មី(ពីរ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដូចតទៅ:

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់អង្គការរៀបចំការបោះឆ្នោត បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលជាសមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវអនុវត្តតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

**មាត្រា ៣.-ថ្មី**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តង ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ លើកលែងតែនៅក្នុងស្ថានភាពណាមួយដូចខាងក្រោម :

- ក្នុងករណីប្រធានស័ក្តិដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត ។
- ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសតាំងរដ្ឋសភាថ្មី ត្រូវប្រព្រឹត្តទៅក្នុងរយៈពេលហុកសិប (៦០)ថ្ងៃ យ៉ាងយូរចាប់ពីថ្ងៃរំលាយរដ្ឋសភា ។
- ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសឱ្យបន្តនីតិកាលរបស់ខ្លួន ស្របតាមកថាខណ្ឌទី ៥ មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៤.-**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានចែងក្នុងជំពូកទី៣ នៃច្បាប់នេះ ។

# ជំពូកទី ២
## ប្រព័ន្ធបោះឆ្នោត និងការកំណត់អាសនៈ

**មាត្រា ៥.-**

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមខេត្ត ក្រុង ដោយយកខេត្ត ក្រុង ជាមណ្ឌលបោះឆ្នោត ។

**មាត្រា ៦_**

អាសនៈនៅក្នុងរដ្ឋសភាមានចំនួនយ៉ាងតិច មួយរយម្ភៃ ( ១២០ ) ។

**មាត្រា ៧_**

រៀងរាល់ឆ្នាំទី៣ នៃនីតិកាលរបស់រដ្ឋសភា គណៈរដ្ឋមន្ត្រីត្រូវបង្កើតគណៈកម្មការកំណត់អាសនៈរដ្ឋសភា ដើម្បីធ្វើការកែប្រែចំនួនអាសនៈ និងបែងចែកអាសនៈតាមខេត្ត ក្រុង ។

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម ៖

- តំណាងមួយរូបនៃគណបក្សនយោបាយនីមួយៗ ដែលមានអាសនៈក្នុងរដ្ឋសភា ។
- តំណាងក្រសួងមហាផ្ទៃពីររូប ។
- នាយកនៃវិទ្យាស្ថានជាតិស្ថិតិ ។

គណៈកម្មការនេះដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយរូប ដែលជ្រើសតាំងក្នុងចំណោមសមាជិកគណៈកម្មការដោយការបោះឆ្នោតតាមមតិភាគច្រើនដាច់ខាតពីសមាជិកគណៈកម្មការនេះ ។

គណៈកម្មការនេះត្រូវធ្វើរបាយការណ៍ និងលើកសំណើអំពីការបន្ថែមអាសនៈ ឬការរក្សាទុកចំនួនអាសនៈនៅដដែលជូនរដ្ឋាភិបាល ដោយផ្អែកលើស្ថានភាពប្រជាពលរដ្ឋ ស្ថានភាពភូមិសាស្ត្រ សង្គម និង សេដ្ឋកិច្ច ។

រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីព្រាងច្បាប់ស្តីពីការកំណត់ចំនួនអាសនៈនេះជូនរដ្ឋសភាអនុម័ត ។

ក្នុងករណីខកខានពុំបានកំណត់ជាថ្មីនូវចំនួនអាសនៈក្នុងរដ្ឋសភា ចំនួនអាសនៈនោះត្រូវយកតាមចំនួនអាសនៈរដ្ឋសភាដែលមានក្នុងនីតិកាលចុងក្រោយ ។

**មាត្រា ៨_**

ចំនួនអាសនៈដែលត្រូវមាននៅក្នុងរដ្ឋសភា និងចំនួនអាសនៈដែលត្រូវបែងចែកតាមខេត្ត ក្រុង ត្រូវផ្សព្វផ្សាយជាសាធារណៈយ៉ាងតិចមួយឆ្នាំ មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៩_**

ក្នុងការរកចំនួនអាសនៈថ្មីរបស់រដ្ឋសភា ត្រូវគណនាតាមរូបមន្តដូចខាងក្រោមដោយមិនគិតចំនួនសល់ ៖

$$\frac{ប_ម}{ច_ម} = ផ$$

- $ប_ម$ ជាចំនួនប្រជាពលរដ្ឋខ្មែរ នៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយកន្លងមកនេះ ។
- $ច_ម$ ជាចំនួនអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន ។
- ផ ជាផលចែកប្រភាគដោយពុំគិតចំនួនសល់ ។

$$\frac{ប_ប}{ផ} = ច_ថ$$

- $ប_ប$ ជាចំនួនប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន ។
- $ច_ថ$ ជាចំនួនអាសនៈថ្មីដោយពុំគិតចំនួនសល់ ។

ក្នុងការរកចំនួនអាសនៈតាមខេត្ត ក្រុង ត្រូវគណនាតាមរូបមន្តដូចខាងក្រោម ៖

$$\frac{ប}{ផ} = ច$$

- ប ជាចំនួនប្រជាពលរដ្ឋខ្មែរក្នុងខេត្ត ក្រុង ។
- ផ ជាផលចែកប្រភាគដែលបានមកពីការគណនាខាងលើ ។
- ច ជាចំនួនអាសនៈថ្មីក្នុងខេត្ត ក្រុង ដោយពុំគិតចំនួនសល់។

**មាត្រា ១០_**

ចំពោះខេត្ត ក្រុងណាដែលមានប្រជាពលរដ្ឋតិចជាងផលចែកប្រភាគ ក៏ត្រូវមានអាសនៈមួយដែរ។

ចំពោះអាសនៈដែលនៅសល់ គណៈកម្មការកំណត់អាសនៈរដ្ឋសភា អាចធ្វើសំណើបន្ថែមអាសនៈទៅខេត្ត ក្រុង ដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រ សង្គម និង សេដ្ឋកិច្ច ។

## ជំពូកទី ៣
## ការគ្រប់គ្រងការបោះឆ្នោត

**មាត្រា ១១_**

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវគ្រប់គ្រងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហៅកាត់ " គ.ជ.ប " ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ដើម្បីអនុវត្តការងាររបស់ខ្លួន ។

**មាត្រា ១២_**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាអង្គការឯករាជ និងអព្យាក្រឹតក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ។

សមាជិកទាំងឡាយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹតឥតលំអៀងក្នុងការអនុវត្តការងារបោះឆ្នោត ។

**មាត្រា ១៣ ថ្មី (ពីរ)_**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាពដូចតទៅ :

- ឥស្សរជនខ្មែរមួយរូប ប្រធាន
- ឥស្សរជនខ្មែរមួយរូប អនុប្រធាន
- ឥស្សរជនខ្មែរប្រាំពីររូប សមាជិក

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសមត្ថភាពខាងនយោបាយ បទពិសោធន៍ក្នុងការងារ និងមានកេរ្តិ៍ឈ្មោះល្អ ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងតិចប្រាំពីរ ( ៧ ) ខែ មុនថ្ងៃបោះឆ្នោតតាមសំណើរបស់គណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានកាតព្វកិច្ចដាក់ជូនគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងតិចប្រាំបួន (៩) ខែ មុនថ្ងៃបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិជ្រើសរើសបុគ្គលិកតាមការចាំបាច់ សម្រាប់ដំណើរការបោះឆ្នោត និងមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

**មាត្រា ១៤.-**

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្មីឱ្យបានសម្រេចយ៉ាងយូរ ហុកសិប ( ៦០ ) ថ្ងៃ បន្ទាប់ពីថ្ងៃរំលាយរដ្ឋសភា ។

**មាត្រា ១៥.-ថ្មី**

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាសមាជិកនៃគណបក្សនយោបាយ ឬ/និងជាអ្នកស្ថិតក្នុងជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគម សហជីព ឬ/និងជាមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំងក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសុំលាលែងជាស្ថាពរពីគណបក្សនយោបាយ ឬ/និងពីជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគម សហជីព ឬ/និងដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌ រហូតដល់ថ្ងៃចប់អាណត្តិ ។ ប្រធាន អនុប្រធាននិងសមាជិកនៃគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោតដែលជាសមាជិកនៃគណបក្សនយោបាយ ឬ/និងជាមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវសុំលាលែងពីសមាជិកនៃគណបក្សនយោបាយជាបណ្តោះអាសន្ន ឬ/និងដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច ។

ប្រធាន ឬអនុប្រធាន ឬសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយដូចខាងក្រោម ៖

- សាមីខ្លួនទទួលមរណភាព ។
- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរ ។
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។
- សាមីខ្លួនប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុង ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការសម្រេចបណ្តេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសមត្ថកិច្ចរបស់រដ្ឋសភា ។

ការសម្រេចបណ្តេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោតជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

- សាមីខ្លួនត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ។

ក្នុងករណីដែលមានប្រធាន ឬអនុប្រធាន ឬសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាត់បង់ពីមុខតំណែង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវដាក់ស្នើបេក្ខភាពថ្មី ក្នុងរយៈពេលយ៉ាងយូរដប់ ( ១០ ) ថ្ងៃ ទៅគណៈរដ្ឋមន្ត្រី ។ រយៈពេលនេះអាចពន្យារដល់សាមសិប ( ៣០ ) ថ្ងៃ ក្នុងករណីដែលគ្មានការរៀបចំបោះឆ្នោត ។

គណៈរដ្ឋមន្ត្រីត្រូវដាក់ស្នើបេក្ខភាពថ្មីទៅរដ្ឋសភា ក្នុងរយៈពេលយ៉ាងយូរប្រាំ ( ៥ ) ថ្ងៃ បន្ទាប់ពីបានទទួលសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ រយៈពេលនេះអាចពន្យារដល់ដប់ប្រាំ ( ១៥ ) ថ្ងៃ ក្នុងករណីដែលគ្មានការរៀបចំបោះឆ្នោត ។

ប្រធាន ឬអនុប្រធាន ឬសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានទទួលការតែងតាំងជំនួសកន្លែងដែលទំនេរនេះ ត្រូវចូលកាន់តំណែងភ្លាម ។

ក្នុងករណីដែលមានប្រធាន ឬអនុប្រធាន ឬសមាជិកនៃគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់ រៀបចំការបោះឆ្នោតបាត់បង់មុខតំណែង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសអ្នកជំនួសតាមបទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៨ថ្មី និងវាក្យខ័ណ្ឌទី១ មាត្រា ២០ថ្មី នៃច្បាប់នេះ ។

## មាត្រា ១៦_ថ្មី

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលខុសត្រូវធ្វើផែនការ រៀបចំ និងចាត់ចែងការបោះឆ្នោតក្នុងទូទាំងប្រទេស ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិពេញលេញក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន ។ សិទ្ធិអំណាច ភារកិច្ចនិងការទទួលខុសត្រូវទាក់ទងនឹងផែនការកម្ម ការរៀបចំការចាត់ចែងនិងការត្រួតពិនិត្យការបោះឆ្នោតមានដូចតទៅ ៖

១_ ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

២_ រៀបចំគំរោងផែនការការងារ ថវិកា និងសម្ភារៈបំរើឱ្យការបោះឆ្នោត ផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

៣_ តែងតាំងគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ។

៤_ ធ្វើបទបញ្ជា នីតិវិធី និងសេចក្តីណែនាំនានាសម្រាប់ដំណើរការបោះឆ្នោតក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

៥_ លើកវិធានការ និងចាត់ចែងការងារដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

៦_ ត្រួតពិនិត្យការងាររបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៧_ កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

៨_ ចេញសេចក្តីសំរេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ។

៩_ ផលិត និងបែងចែកសម្ភារៈ បរិក្ខារបំរើឱ្យការងារបោះឆ្នោត ។

១០_ ជ្រើសរើស និងតែងតាំងមន្ត្រីចុះជួយពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមច្បាប់ និងបទបញ្ជា ។

១១_ រៀបចំបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

១២_ ពិនិត្យ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោត ។

១៣_ ទទួល និងសំរេចលើពាក្យសុំឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ និងការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្ររបស់គណបក្សនយោបាយ ។

១៤_ ត្រួតពិនិត្យ និងសម្របសម្រួលការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត ។

១៥_ រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនិងការប្រកាសលទ្ធផល ។

១៦_ ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ ។

ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។

លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះឡើងវិញ ។

១៧_ ត្រួតពិនិត្យចំណូលនិងចំណាយក្នុងពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ ។

១៨_ ចាត់វិធានការ និងសម្របសម្រួលដើម្បីឱ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនាសាធារណៈតាមគោលការណ៍ស្មើភាព ។

១៩_ ផ្តល់ព័ត៌មានអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។

ធានាឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំអំពីកិច្ចដំណើរការបោះឆ្នោតរវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែល ពាក់ព័ន្ធនានា ។

២០_ ផលិតឯកសារផ្សព្វផ្សាយអំពីការងារបោះឆ្នោត ។

២១_ លើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារបោះឆ្នោត តាមរយៈការអប់រំនិងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត ។

២២_ រៀបចំឯកសារ កម្មវិធី និងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត ។

២៣_ ពិនិត្យសំរេច និងចេញប័ណ្ណសម្គាល់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ។

២៤_ ត្រួតពិនិត្យភាពត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងតាមនីតិវិធីនៃការអនុវត្តការងារបោះឆ្នោត ។

២៥_ សំរេចដោយបើកសវនាការជាសាធារណៈលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

២៦_ បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

២៧_ រៀបចំគណៈកម្មការដើម្បីបំផ្លាញសន្លឹកឆ្នោត ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះរយៈពេលបួន ( ៤ ) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោតតាមអាណត្តិនីមួយៗ ដោយមានការចូលរួមពីតំណាងគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ។

២៨_ អនុវត្តការងារដទៃទៀតដែលច្បាប់ និងបទបញ្ជាអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

**មាត្រា ១៧_ថ្មី**

របៀបរបបធ្វើការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ និងតាមបទបញ្ជា ។ ក្នុងករណីដែលប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអវត្តមាន ត្រូវធ្វើការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរតាមឋានានុក្រម ក្នុងជួរគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ការប្រជុំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចយកជាការបាន លុះត្រាតែមានកូរ៉ុមពីរភាគបី ( ២/៣ ) នៃសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ករណីមិនគ្រប់កូរ៉ុមសម្រាប់ការប្រជុំណាមួយ ការប្រជុំនោះត្រូវកោះអញ្ជើញលើកទី ២ នៅថ្ងៃបន្ទាប់ជាបន្ទាន់ ហើយកូរ៉ុមសម្រាប់ការប្រជុំលើកទីពីរនេះ ត្រូវមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងមូល ។ រាល់ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចយកជាការបាន លុះត្រាតែមានមតិភាគច្រើនដាច់ខាតយល់ព្រម ។

**មាត្រា ១៨_ថ្មី**

សមាសភាពគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបានតែងតាំងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងចំណោមប្រជាពលរដ្ឋ មន្ត្រីរាជការ ឬ/និង អ្នកមុខអ្នកការក្នុងខេត្ត ក្រុង ដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ។

សមាសភាពនៃគណៈកម្មការខេត្ត ក្រុងនេះត្រូវមានប្រធានមួយ ( ១ ) រូប អនុប្រធានមួយ ( ១ ) រូប និងសមាជិកពីបី ( ៣ ) ទៅប្រាំ ( ៥ ) រូប ។ គណៈកម្មការខេត្ត ក្រុងនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ។

ក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យមន្ត្រីលេខាធិការដ្ឋានមួយ ( ១ ) រូប ឬពីរ ( ២ ) រូប ដើម្បីបន្តនិរន្តរភាពការងារបោះឆ្នោតនៅតាមខេត្ត ក្រុង ។

**មាត្រា ១៩_**

ភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតមានដូចតទៅ ៖

១_ អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជានិងលិខិតបទដ្ឋាននានាអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

២_ អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យ។

**មាត្រា ២០_ថ្មី**

សមាសភាពគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបានតែងតាំងឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតក្នុងចំណោមប្រជាពលរដ្ឋ មន្ត្រីរាជការ ឬ/និងអ្នកមុខអ្នកការក្នុងស្រុក ខណ្ឌ ឃុំ សង្កាត់ដែលមានសិទ្ធិបោះឆ្នោតលើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ។

សមាសភាពគណៈកម្មការនេះមានប្រធានមួយ ( ១ ) រូប អនុប្រធានមួយ ( ១ ) រូប និងសមាជិកបី ( ៣ ) រូប ។

**មាត្រា ២១_**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមានភារកិច្ច និងការទទួលខុសត្រូវ ដូចតទៅ ៖

១_ អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជានិងលិខិតបទដ្ឋាននានាអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

២_ អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យ។

**មាត្រា ២២_ថ្មី**

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបានតែងតាំងឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសំណើរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្នុងចំណោមប្រជាពលរដ្ឋ មន្ត្រីរាជការក្នុងស្រុក ខណ្ឌ ឃុំ សង្កាត់ដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីដែលបំរើការងាររដ្ឋបាលក្នុងសាលាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ។

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រធានមួយ ( ១ ) រូប អនុប្រធានមួយ ( ១ ) រូប លេខាធិការមួយ ( ១ ) រូប និងសមាជិកពីរ ( ២ ) រូប តាមការចាំបាច់ និងការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៣_**

ភារកិច្ចនិងការទទួលខុសត្រូវរបស់គណៈកម្មការការិយាល័យបោះឆ្នោតមានដូចតទៅ ៖

១_ អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជានិងលិខិតបទដ្ឋាននានាអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

២_ អនុវត្តភារកិច្ចនិងសិទ្ធិផ្សេងៗទៀត ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យ។

**មាត្រា ២៤_**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចចេញសេចក្តីសំរេចប្រគល់សិទ្ធិរបស់ខ្លួនដល់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោតនិងមន្ត្រី ឬភ្នាក់ងារបំរើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត ។

**មាត្រា ២៥_**

បេក្ខជនឈរឈ្មោះបោះឆ្នោតជាតំណាងរាស្ត្រ ឬសមាជិកគណៈកម្មាធិការនាយក នៃគណបក្សនយោបាយ មិនអាចចូលរួមក្នុងសមាភាពគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតបានឡើយ ។

**មាត្រា ២៦_ថ្មី**

គណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោត អាចបញ្ជូនតំណាងរបស់ខ្លួនពីរ ( ២ ) រូប ពេញសិទ្ធិមួយ ( ១ ) រូប និងបម្រុងមួយ ( ១ ) រូប ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោត ចូលរួមសង្កេតការណ៍មើលការបោះឆ្នោត តាមការិយាល័យបោះឆ្នោតនីមួយៗ ។

តំណាងពេញសិទ្ធិត្រូវបានអនុញ្ញាតអោយចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ។

តំណាងបម្រុងត្រូវបានអនុញ្ញាតអោយជំនួសតំណាងពេញសិទ្ធិ ក្នុងករណីដែលតំណាងពេញសិទ្ធិអវត្តមាន ។

គណបក្សនយោបាយនីមួយៗ មានសិទ្ធិផ្លាស់ប្តូរតំណាងរបស់ខ្លួន ។

**មាត្រា ២៧_**

អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ អង្គការអន្តរជាតិនិងប្រទេសនានាអាចបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមជាអ្នកសង្កេតការណ៍ការបោះឆ្នោត ។

**មាត្រា ២៨_**

តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ អង្គការអន្តរជាតិនិងប្រទេសនានា ដែលចូលរួមសង្កេតការណ៍បោះឆ្នោតត្រូវមានការទទួលស្គាល់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៩_ថ្មី**

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតតាមសំណើរបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

**មាត្រា ៣០_**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧបនាយករដ្ឋមន្ត្រី ។ អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈនិងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី ។ សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈនិងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ ។ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈនិងបុព្វសិទ្ធិស្មើនឹងអគ្គនាយកក្រសួង ។

**មាត្រា ៣១_**

សមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដទៃទៀត ព្រមទាំងបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន លេខាធិការដ្ឋាន ត្រូវបានទទួលប្រាក់កម្រៃតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣២_ថ្មី(ពីរ)**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបំពេញការងាររបស់ខ្លួន រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរ ។

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់ហុកសិប (៦០)ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ ។

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបន្តការងាររបស់ខ្លួនរហូតដល់មានការតែងតាំងថ្មី ។

ក្នុងករណីខកខានមិនបានរៀបចំសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមពេលវេលាដូចបានបញ្ញត្តក្នុងវាក្យខ័ណ្ឌទី ៣ មាត្រា ១៣ថ្មី(ពីរ)នៃច្បាប់នេះ សមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវបន្តការងារ និងមានសមត្ថកិច្ចចាត់ចែងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតផ្សេងទៀតតាមច្បាប់តម្រូវ ។

# ជំពូកទី ៤

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

**មាត្រា ៣៣_ថ្មី**

ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រត្រូវបំពេញលក្ខខ័ណ្ឌដូចខាងក្រោម ៖

១_ មានសញ្ជាតិខ្មែរពីកំណើត ។

២_ មានអាយុម្ភៃប្រាំ (២៥) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត ។

៣_ មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

៤_ មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥_ មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ។

**មាត្រា ៣៤_ថ្មី**

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៖

១_ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ ក្នុងមុខតំណែង និងបព្វជិតសាសនាឬ

២_ ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញឬ

៣_ ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោតឬ

៤_ ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ចឬ

៥_ ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឬ

៦_ សមាជិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឬ

៧_ សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឬ

៨_ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៣៥_ថ្មី**

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនាដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរ យ៉ាងតិចប្រាំពីរ ( ៧ ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមីអង្គភាព ទៅបម្រើការក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីខ្លួនត្រូវមានសិទ្ធិឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រលប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

**មាត្រា ៣៦_ថ្មី**

បែបបទនៃការអនុវត្តមាត្រា ៣៣ថ្មី មាត្រា ៣៤ថ្មី នៃច្បាប់នេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣៧_ថ្មី**

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវចាប់ផ្ដើមកៅសិប ( ៩០ ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាផ្លូវការ គណបក្សនយោបាយត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមបែបបទកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងយូរចិតសិប ( ៧០ ) ថ្ងៃ មុនថ្ងៃបោះឆ្នោតដោយភ្ជាប់មកជាមួយ ៖

១_ សេចក្ដីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃមួយច្បាប់ ។

២_ ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់និងសញ្ញាសម្គាល់គណបក្សនយោបាយ ។

៣_ អាសយដ្ឋាននៃទីស្នាក់ការកណ្ដាលរបស់គណបក្សនយោបាយ ។

៤_ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបទូទាំងប្រទេស ។ បញ្ជីនេះត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិចមួយភាគបី ( ១/៣ ) នៃចំនួនអាសនៈក្នុងរដ្ឋសភា និងបេក្ខជនបម្រុង ចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ ។

៥_ ឈ្មោះមណ្ឌលដែលគណបក្សនយោបាយមានបំណងទៅឈរ និងបញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលទាំងនោះ ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលត្រូវមានចំនួនបេក្ខជន គ្រប់តាមចំនួនកំណត់អាសនៈ និងតាមគំរូដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្ដល់ឱ្យ ។

ចំពោះមណ្ឌលបោះឆ្នោតដែលមានអាសនៈមួយ ( ១ ) ឬពីរ ( ២ ) ត្រូវមានបេក្ខជនបម្រុងចំនួនយ៉ាងតិចបី ( ៣ ) រូប ។

៦_ សេចក្ដីប្រកាសអំពីគណនីធនាគារ ដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗ រួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

៧_ លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ពីការបង្កើតគណបក្សនយោបាយ ។

៨_ សេចក្ដីប្រកាសរបស់គណបក្សនយោបាយសន្យាថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលនៃការបោះឆ្នោតដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងចូលរួមអនុវត្តច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រមសីលធម៌ និងច្បាប់ស្ដីពីគណបក្សនយោបាយ ។

៩_ បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ ។

១០_ បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួនដប់ប្រាំលាន ( ១៥.០០០.០០០ ) រៀលដែលចេញដោយរតនាគារជាតិ ។ ប្រាក់តម្កល់នេះត្រូវបានបង្វិលជូនទៅសាមីគណបក្សនយោបាយវិញ ក្នុងករណីដែលគណបក្សនយោបាយនោះបានទទួលសន្លឹកឆ្នោតយ៉ាងតិចបីភាគរយ ( ៣% ) នៃចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈមួយក្នុងរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវប្រព្រឹត្តទៅក្នុងរយៈពេលដប់ ( ១០ ) ថ្ងៃ គិតពីថ្ងៃប្រកាសរំលាយរដ្ឋសភា ។

**មាត្រា ៣៨_ថ្មី**

បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលត្រូវ ៖

១_ ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។

២_ មានសេចក្ដីបញ្ជាក់អំពីការចុះឈ្មោះបោះឆ្នោត ដោយអាជ្ញាធរឃុំ សង្កាត់ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត ។

៣_ ភ្ជាប់សេចក្ដីប្រកាសរបស់បេក្ខជនយល់ព្រមទទួលការតែងតាំងជាបេក្ខជន តាមមណ្ឌលរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

**មាត្រា ៣៩_**

បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់មណ្ឌលតែមួយគត់ ។

បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះលើសពីមួយមណ្ឌល ត្រូវបានប្រកាសថាបាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទោះជាសាមីខ្លួនទៅឈរឈ្មោះជាបេក្ខជនក្នុងគណបក្សនយោបាយណាផ្សេងទៀតក៏ដោយ ។

**មាត្រា ៤០_ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ ( ៧ ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជាបន្ទាន់ ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនសាមីគណបក្សនយោបាយ ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយនោះពុំបានបំពេញលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងមាត្រា ៣៣ថ្មី មាត្រា ៣៤ថ្មី មាត្រា ៣៥ថ្មី មាត្រា ៣៦ថ្មី មាត្រា ៣៧ថ្មី និងមាត្រា ៣៨ថ្មី នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញ ដើម្បីបំពេញបន្ថែម ។

គណបក្សនយោបាយនេះត្រូវបំពេញលក្ខខណ្ឌដែលខ្វះខាត យ៉ាងយូរប្រាំ ( ៥ ) ថ្ងៃ បន្ទាប់ពីថ្ងៃដែលសាមីគណបក្សនយោបាយបានទទួលលិខិតជូនដំណឹង ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណបក្សនយោបាយត្រូវបំពេញលក្ខខណ្ឌដែលខ្វះខាតឱ្យទាន់មុនពេលបញ្ចប់បញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

ផុតកំណត់នេះ បើគណបក្សនយោបាយពុំបានបំពេញលក្ខខណ្ឌទាំងនោះទេ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាត់ទុកថា គណបក្សនយោបាយនោះបោះបង់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

**មាត្រា ៤១_ថ្មី**

ប្រសិនបើបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនណាមួយត្រូវបានបដិសេធ តាមបទប្បញ្ញត្តិនៃមាត្រា ៣៣ថ្មី ឬមាត្រា ៣៤ថ្មី ឬមាត្រា ៣៥ថ្មី ឬមាត្រា ៣៩នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- បំពេញបែបបទនៃការបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។
- ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅសាមីខ្លួន និងសាមីគណបក្សនយោបាយ ។
- ផ្តល់ព័ត៌មានដល់សាមីខ្លួន និងទៅសាមីគណបក្សនយោបាយថា អនុលោមតាមមាត្រា ៤២ថ្មីនៃច្បាប់នេះ សាមីខ្លួន ឬសាមីគណបក្សនយោបាយអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួន ឬសាមីគណបក្សនយោបាយ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់ ។

- ផ្ញើសេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៤២_ថ្មី**

បេក្ខភាពណាដែលត្រូវបានបដិសេធ ឬបញ្ជីរាយនាមបេក្ខជនរបស់គណបក្សនយោបាយណាដែលត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សាមីខ្លួន ឬសាមីគណបក្សនយោបាយនោះមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួន ឬសាមីគណបក្សនយោបាយ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេលដប់ ( ១០ ) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះជាបន្ទាន់ ។

**មាត្រា ៤៣_**

សវនាការឬផ្នែកមួយនៃសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលវិនិច្ឆ័យទៅលើបណ្តឹងតវ៉ា ត្រូវធ្វើជាចំហ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបិទផ្សាយថ្ងៃ ខែ ឆ្នាំ ទីកន្លែងនិងពេលវេលានៃការបើកសវនាការវិនិច្ឆ័យលើបណ្តឹងតវ៉ានេះ ។

**មាត្រា ៤៤_**

បន្ទាប់ពីបានបញ្ឈប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬនិងក្រោយពេលដែលបណ្ដឹងតវ៉ាត្រូវបានដោះស្រាយជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមខេត្ត ក្រុង របស់គណបក្សនយោបាយទាំងនោះទៅតាមការកំណត់ដូចមានចែងក្នុងបទបញ្ជា និងនីតិវិធី ។

## ជំពូកទី ៥
## ការិយាល័យបោះឆ្នោត

**មាត្រា ៤៥_ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចបង្កើតការិយាល័យបោះឆ្នោត មួយឬច្រើនសម្រាប់ឃុំ សង្កាត់នីមួយៗ ស្របតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ ។

ការិយាល័យបោះឆ្នោត និងតំបន់ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៤៦_ថ្មី**

**ក.** ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតយ៉ាងច្រើនប្រាំពីររយ (៧០០) នាក់ ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវប្រមូលផ្ដុំដោយភូមិទាំងមូល និងត្រូវបង្កលក្ខណៈឱ្យសមាជិកទាំងអស់របស់គ្រួសារក្នុងភូមិនោះបានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពីប្រាំពីររយ ( ៧០០ ) នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះ ទៅក្នុងការិយាល័យបោះឆ្នោតដែលជិតបំផុតក្នុងឃុំ សង្កាត់ជាមួយ ។

**ខ.** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិជ្រើសយកបរិវេណ ឬអគារតែមួយធ្វើជាការិយាល័យបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតពីរ ឬច្រើន ប្រសិនបើមិនធ្វើឱ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ។

ការិយាល័យបោះឆ្នោតជាច្រើនដែលតាំងនៅបរិវេណ ឬអគារតែមួយនោះត្រូវរៀបចំឱ្យស្ថិតនៅដាច់ដោយឡែកពីគ្នា ។

ការិយាល័យបោះឆ្នោតនីមួយៗដែលតាំងនៅបរិវេណ ឬអគារតែមួយនោះត្រូវគ្រប់គ្រងឱ្យដាច់ចេញពីគ្នា និងខុសពីការិយាល័យបោះឆ្នោតផ្សេងទៀត ទៅតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៧_ថ្មី**

ឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតដែលបានកំណត់ហើយ ត្រូវបិទផ្សាយជាសាធារណៈ ។

គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតអាចសុំតារាងឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនេះបានដោយបង់ថ្លៃ ។

តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ជូនតារាងឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនៃមណ្ឌលនីមួយៗ មួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ៦
## ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត

**មាត្រា ៤៨_ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឱ្យមានបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដែលបង្កើតឡើងតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៤៥ថ្មី និងមាត្រា ៤៦ថ្មីនៃច្បាប់នេះ។

បញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវកត់ចូលក្នុងសៀវភៅបញ្ជីមួយ ហើយរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ តាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីឈ្មោះបោះឆ្នោតផ្លូវការកៅសិប ( ៩០ ) ថ្ងៃ យ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនអាណត្តិ បញ្ជីបោះឆ្នោតត្រូវយកបញ្ជីបោះឆ្នោតដែលមានសុពលភាពចុងក្រោយទុកជាផ្លូវការ ហើយត្រូវផ្សព្វផ្សាយបញ្ជីនេះយ៉ាងតិចហាសិប ( ៥០ ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៤៩._ថ្មី(ពី)**

សៀវភៅបញ្ជីនេះ ត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ ហើយត្រូវថតចម្លងផ្លូវការមួយច្បាប់ រក្សាទុកនៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវធ្វើចាប់ពីថ្ងៃទី ០១ ខែតុលា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចកាលបរិច្ឆេទ និងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្សេងពីនេះ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតយ៉ាងយូរសាមសិប (៣០)ថ្ងៃ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឬប្រធានសក្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងពីនេះ ។

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបង្កើតថ្មីដែលត្រូវកែប្រែព្រំប្រទល់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងលក្ខខណ្ឌដែលចែងក្នុងច្បាប់នេះ និងបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៥០_ថ្មី**

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនក្នុងពេលបោះឆ្នោត ។

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ ។
- មានអាយុ ១៨ ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត ។
- មានទីលំនៅក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត ។
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ។
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបទបញ្ជា និងនីតិវិធីដើម្បីអនុវត្តជាក់ស្តែងនូវវាក្យខណ្ឌទី១ នៃមាត្រានេះ ។

**មាត្រា ៥១_ថ្មី**

បេក្ខជនដែលឈរឈ្មោះបោះឆ្នោត សហព័ទ្ធ និងកូនអាចទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែលខ្លួនឈរឈ្មោះបោះឆ្នោតបាន ។

បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ ដែលបានអនុម័តយល់ព្រមឱ្យចុះបញ្ជីឈរឈ្មោះដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួនដែលបានចុះឈ្មោះបោះឆ្នោត នៅមណ្ឌលបោះឆ្នោតផ្សេងពីមណ្ឌលដែលខ្លួនឈរឈ្មោះ បេក្ខជននោះអាចធ្វើសេចក្តីស្នើសុំមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យចុះឈ្មោះរបស់ខ្លួនព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ក្នុងករណីមានការយល់ព្រមពីសហព័ទ្ធ និងកូនរបស់ខ្លួននៅការិយាល័យបោះឆ្នោតណាមួយក្នុងមណ្ឌលដែលខ្លួនឈរឈ្មោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឱ្យលុបឈ្មោះរបស់បេក្ខជន សហព័ទ្ធ និងកូនរបស់បេក្ខជននោះចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ដែលបានចុះឈ្មោះកន្លងមក រួចហើយចាត់ឱ្យចុះឈ្មោះបេក្ខជន សហព័ទ្ធនិងកូនរបស់បេក្ខជននោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងមណ្ឌលដែលបេក្ខជននោះឈរឈ្មោះតាមការស្នើសុំ ។

**មាត្រា ៥២_ថ្មី**

ប្រជាពលរដ្ឋខ្មែរម្នាក់ៗ ត្រូវមានឈ្មោះតែមួយ ក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់ ។

ប្រជាពលរដ្ឋខ្មែរដែលមានទីលំនៅច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសយកកន្លែងតែមួយគត់ដើម្បីចុះឈ្មោះជាអ្នកបោះឆ្នោត ។

**មាត្រា ៥៣_ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបំពេញតួនាទីជាតំណាងខ្លួន ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ ។

ដើម្បីអនុវត្តតួនាទីខាងលើនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រគល់ភារកិច្ចដល់ស្មៀនឃុំ សង្កាត់របស់ខ្លួនឱ្យទទួលជាមន្ត្រីពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំស្មៀនឃុំ សង្កាត់ ឱ្យអនុវត្តឱ្យបានត្រឹមត្រូវនូវច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនមួយ ( ១ ) រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាប្រាំ ( ៥ ) រូប និងពីរ ( ២ ) រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សា ចាប់ពីប្រាំពីរ ( ៧ ) រូបឡើងទៅ ឱ្យប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រចាំការនេះមិនទទួលប្រាក់កំរៃបន្ថែមឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ អំពីការធ្វើប្រតិភូកម្មអំណាចស្របតាមសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសមស្របដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ដើម្បីអនុវត្តការទទួលខុសត្រូវនេះ ។

**មាត្រា ៥៤_ថ្មី(ពីរ)**

**ក_**ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋត្រូវទៅបង្ហាញខ្លួននៅសាលាឃុំ សង្កាត់របស់ខ្លួន ឬទីកន្លែងណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ពេលបង្ហាញខ្លួនប្រជាពលរដ្ឋត្រូវ:

_បង្ហាញអត្តសញ្ញាណរបស់ខ្លួនដល់ស្មៀនឃុំ សង្កាត់ ។

_មានសិទ្ធិបោះឆ្នោតស្របតាមមាត្រា ៥០ ថ្មី នៃច្បាប់នេះ ។

_មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់ ។

ក្នុងករណីដែលមានប្រជាពលរដ្ឋដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្តោះអាសន្ន នូវសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដែលបានផ្លាស់ទីលំនៅចេញទៅឃុំ សង្កាត់ផ្សេង ស្មៀនឃុំ សង្កាត់ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក ហើយក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៤៩ថ្មី(បី)នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ត្រូវលុបឈ្មោះប្រជាពលរដ្ឋទាំងនោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។

ចំពោះប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះពីមុនមក ដែលទើបដល់អាយុត្រូវបោះឆ្នោត ដែលបានផ្លាស់ទីលំនៅចូលថ្មី ស្មៀនឃុំ សង្កាត់ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក ហើយក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋទាំងនោះត្រូវបំពេញលក្ខខ័ណ្ឌសម្រាប់ការចុះឈ្មោះដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ និងវាក្យខ័ណ្ឌទី ២ នៃមាត្រានេះ ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ឱ្យធ្វើការចុះឈ្មោះចល័តស្របតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**ខ**_ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយ ដូចខាងក្រោម :

_លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

_អត្តសញ្ញាណប័ណ្ណដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា ដោយមានបិទរូបថតជាសំគាល់ ។

_សៀវភៅគ្រួសារ ។

ប្រជាពលរដ្ឋដែលមកបង្ហាញខ្លួន អាចកំណត់អត្តសញ្ញាណរបស់ខ្លួនបាន ដោយការធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីររូបក្នុងឃុំ សង្កាត់នោះ ធ្វើឡើងនៅចំពោះមុខមេឃុំ ចៅសង្កាត់ ឬចំពោះមុខជំទប់ ចៅសង្កាត់រង ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមាន ដោយបញ្ជាក់ថាអ្នកសុំចុះឈ្មោះនោះពិតជាមនុស្សដូចដែលសាមីខ្លួនបានបញ្ជាក់អះអាងមែន រួចហើយត្រូវយកលិខិតបញ្ជាក់នោះមកបង្ហាញស្មៀនឃុំ សង្កាត់ភ្លាម ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត ។

**គ**_ដើម្បីបញ្ជាក់ថាខ្លួនជាប្រជាពលរដ្ឋខ្មែរ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយក្នុងចំណោមឯកសារដូចខាងក្រោម :

_លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

_អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលបានផ្តល់ឱ្យអនុលោមទៅតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៣៦ អនក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

_អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

_ឆាយារបស់ព្រះសង្ឃ ។

-ភស្តុតាងដែលបង្ហាញថា ឈ្មោះរបស់អ្នកសុំចុះឈ្មោះមាននៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ និងសៀវភៅបញ្ជីបោះឆ្នោតរបស់ឃុំ សង្កាត់ ។

-សំបុត្រកំណើតដែលមានបញ្ជាក់ពីសញ្ជាតិខ្មែរ ។

-លិខិតបញ្ជាក់ថាជាប្រជាពលរដ្ឋខ្មែរ ដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា ។

-លិខិតបញ្ជាក់ ឯកសារ ឬសេចក្តីសម្រេចស្ថាពររបស់តុលាការដែលបញ្ជាក់ថា ឪពុក ឬម្តាយរបស់អ្នកសុំចុះឈ្មោះជាប្រជាពលរដ្ឋខ្មែរ និងឯកសារដែលបង្ហាញថាអ្នកសុំចុះឈ្មោះ គឺជាកូនរបស់ឪពុក ឬម្តាយនោះ ។

-ឯកសារជាផ្លូវការបង្ហាញថា អ្នកសុំចុះឈ្មោះកើតនៅក្នុងប្រទេសកម្ពុជា ហើយឪពុក និងម្តាយបរទេសរបស់ជននោះ ក៏កើត និងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាដែរ និងឯកសារជាផ្លូវការដែលបង្ហាញថាអ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុក និងម្តាយនោះ ។

**ឃ**-ដើម្បីបញ្ជាក់ថាខ្លួនមានអាយុយ៉ាងតិច ១៨ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយដូចខាងក្រោម ៖

-ឯកសារណាមួយដូចមានចែងក្នុងមាត្រា ៥៨ថ្មី(ពីរ) **ខ** និង **គ** នៃច្បាប់នេះ ដែលមានបញ្ជាក់ពីអាយុ ឬថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកសុំចុះឈ្មោះ ឬលិខិតធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីរ ( ២ ) រូប ក្នុងឃុំ សង្កាត់នោះ ធ្វើឡើងចំពោះមុខមេឃុំ ចៅសង្កាត់ ដោយបញ្ជាក់ថាអ្នកសុំចុះឈ្មោះនោះពិតជាមានអាយុ ១៨ឆ្នាំ យ៉ាងតិច គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រប្រាកដមែន ។

**ង**-ដើម្បីបញ្ជាក់ថាខ្លួនពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយដូចខាងក្រោម ៖

-ឯកសារទាំងឡាយដូចមានចែងក្នុងមាត្រា ៥៨ថ្មី(ពីរ) **ខ គ** និង **ឃ** នៃច្បាប់នេះ ហើយដែលបញ្ជាក់ថាអ្នកសុំចុះឈ្មោះពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ឬលិខិតបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់ថាសាមីខ្លួនពិតជាមានទីលំនៅនៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ។

**ច**-ក្នុងករណីដែលប្រជាពលរដ្ឋមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៥៨ថ្មី(ពីរ) **ខ គ ឃ** និង **ង** នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ ត្រូវ ៖

-ចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត ។

-កត់ឈ្មោះប្រជាពលរដ្ឋនោះចូលក្នុងសៀវភៅបញ្ជីបោះឆ្នោត ។

-ចេញបង្កាន់ដៃបញ្ជាក់អំពីការចុះឈ្មោះជូនសាមីខ្លួន ។

-បញ្ជាក់ប្រាប់ប្រជាពលរដ្ឋ អំពីការិយាល័យបោះឆ្នោតដែលប្រជាពលរដ្ឋនោះ ត្រូវទៅបោះឆ្នោត ។

ចំពោះប្រជាពលរដ្ឋណាដែលមានឈ្មោះក្នុងសៀវភៅបញ្ជីបោះឆ្នោតរួចហើយ ស្មៀនឃុំ សង្កាត់គ្រាន់តែពិនិត្យភស្តុតាងនៃការចុះឈ្មោះរបស់ជននោះ ប្រសិនបើជននោះមិនស្ថិតក្នុងករណីណាមួយដូចបានចែងក្នុងវាក្យខ័ណ្ឌទី ៣ មាត្រា ៥៨ថ្មី(ពីរ) **ក** នៃច្បាប់នេះ ស្មៀនឃុំ សង្កាត់ត្រូវធ្វើបច្ចុប្បន្នភាពឈ្មោះរបស់ជននោះចូលក្នុងបញ្ជីបោះឆ្នោត ។

**មាត្រា ៥៥_ថ្មី**

ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហាមឃាត់មិនឱ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ព្រមទាំងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងសាលាឃុំ សង្កាត់ ឬទីកន្លែងកំណត់សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត លើកលែងតែមានជនណាបង្កការអុកឡុករំខាន ទើបមេឃុំ ចៅសង្កាត់ អាចស្នើសុំឱ្យមានអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាឱ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យនានា ។

**មាត្រា ៥៦_ថ្មី(ពីរ)**

ស្មៀនឃុំ សង្កាត់ បន្ទាប់ពីបានសុំយោបល់ពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រចាំការមើលការខុសត្រូវ អាចបដិសេធការចុះឈ្មោះដល់អ្នកមកចុះឈ្មោះ ក្នុងករណីមានភស្តុតាងបញ្ជាក់ថា ជននោះពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមមាត្រា ៥០ថ្មី មាត្រា ៥៤ថ្មី(ពីរ) **ក ខ គ ឃ** និង **ខ** នៃច្បាប់នេះ ។

ក្នុងករណីដែលស្មៀនឃុំ សង្កាត់បដិសេធការចុះឈ្មោះបោះឆ្នោតរបស់ប្រជាពលរដ្ឋ ស្មៀនឃុំ សង្កាត់ត្រូវ :

_បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

_ផ្តល់សេចក្តីចម្លងនៃការបដិសេធមួយច្បាប់ជូនសាមីខ្លួន ។

_ផ្តល់ព័ត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា ៥៧ថ្មី នៃច្បាប់នេះ សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលបី ( ៣ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

_ផ្ញើសំណុំឯកសារបដិសេធមួយច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរយៈលេខាធិការដ្ឋាន គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៥៧_ថ្មី**

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួនត្រូវបានបដិសេធដោយស្មៀនឃុំ សង្កាត់ ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនក្នុងរយៈពេលបី ( ៣ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

**មាត្រា ៥៨_ថ្មី**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ានេះ ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ក្នុងរយៈពេលបី (៣) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

**មាត្រា ៥៩_ថ្មី(ពីរ)**

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់យល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យស្មៀនឃុំ សង្កាត់ អនុវត្តការចុះឈ្មោះតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥៤ថ្មី (ពីរ) **ច** នៃច្បាប់នេះ ។

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ពុំយល់ព្រមតាមសំណើរបស់អ្នកប្ដឹងតវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្ដល់សេចក្ដីចម្លងនៃការបដិសេធមួយច្បាប់ជូនសាមីខ្លួន ។

-ផ្ដល់ព័ត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា ៦០ថ្មី នៃច្បាប់នេះ សាមីខ្លួន ឬតំណាងអាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធមួយច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៦០_ថ្មី**

ជនណាដែលបណ្ដឹងតវ៉ារបស់ខ្លួនត្រូវបានបដិសេធដោយក្រុមប្រឹក្សាឃុំ សង្កាត់ ជននោះ ឬតំណាងអាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

**មាត្រា ៦១_ថ្មី(ពីរ)**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្ដឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ព្រមតាមសំណើរបស់អ្នកប្ដឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញសេចក្ដីសម្រេចទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីចាត់ឱ្យស្មៀនឃុំ សង្កាត់ ចុះឈ្មោះអ្នកដែលត្រូវបានបដិសេធ ដោយអនុវត្តតាមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៥៤ថ្មី (ពីរ) ថ នៃច្បាប់នេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំយល់ព្រមតាមសំណើរបស់អ្នកប្ដឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

-បំពេញបែបបទនៃការបដិសេធដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ។

-ផ្ដល់សេចក្ដីចម្លងនៃការបដិសេធនេះមួយច្បាប់ទៅអ្នកប្ដឹងតវ៉ា ។

-ផ្ដល់ព័ត៌មានទៅសាមីខ្លួនថា អនុលោមតាមមាត្រា ៦២ថ្មី (ពីរ)នៃច្បាប់នេះ សាមីខ្លួន ឬតំណាងអាចប្ដឹងតវ៉ា ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

-ផ្ញើសេចក្ដីចម្លងនៃការបដិសេធនេះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ៦២_ថ្មី(ពីរ)**

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួន ត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលដប់ ( ១០ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រម ឬមិនយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ :

_ចេញសេចក្តីសម្រេចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬបដិសេធឈ្មោះអ្នកដែលមានបញ្ហា ។

_ផ្ញើសេចក្តីចម្លងនៃសេចក្តីសម្រេចយល់ព្រម ឬបដិសេធនេះមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬតំណាង ។

ប្រសិនបើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ តម្រូវឱ្យចុះឈ្មោះអ្នកដែលមានបញ្ហា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចុះឈ្មោះបោះឆ្នោតអ្នកដែលមានបញ្ហានោះតាមលក្ខខ័ណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៥៤ថ្មី (ពីរ) ២ នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនោះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៦៣_ថ្មី**

បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហើយការប្តឹងតវ៉ាទៅនឹងការចុះឈ្មោះត្រូវបានដោះស្រាយរួចរាល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូងនៅសាលាឃុំ សង្កាត់ និងទីតាំងណាមួយក្នុងឃុំ សង្កាត់ តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតថតចម្លងនេះបានដោយបង់ថ្លៃ ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

**មាត្រា ៦៤_ថ្មី(ពីរ)**

ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ជនណាក៏ដោយក៏អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ខ្លួន ពីការបាត់បង់ឈ្មោះ ឬជំទាស់ការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃជនណាម្នាក់ដែលខ្លួនមានភស្តុតាងបញ្ជាក់ថា :

_ជននោះពុំមានលក្ខខ័ណ្ឌត្រឹមត្រូវ គ្រប់គ្រាន់តាមមាត្រា ៥០ថ្មី និងមាត្រា ៥៤ថ្មី (ពីរ) នៃច្បាប់នេះ ។

_ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង ។

_ជននោះបានមកចុះឈ្មោះ មានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែជននោះ គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

_ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែកត់ត្រាមិនច្បាស់លាស់ ។

អ្នកប្តឹងតវ៉ាត្រូវបង្ហាញភស្តុតាងជាឯកសារណាមួយទៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

អ្នកប្តឹងជំទាស់ត្រូវផ្តល់ព័ត៌មានបន្ថែម ក្នុងករណីមានការស្នើសុំពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល ការប្តឹងដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ មានរយៈពេលដប់ (១០)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

**មាត្រា ៦៥_ថ្មី(ពីរ)**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ា ឬជំទាស់ ក្នុងរយៈពេលបី ( ៣ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នេះជាការត្រឹមត្រូវ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យស្មៀនឃុំ សង្កាត់ឱ្យចុះឈ្មោះ អ្នកដែលមានបញ្ហានោះក្នុងបញ្ជីបោះឆ្នោត ឬលុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើអ្នកតវ៉ា ឬជំទាស់ ឬអ្នកដែលមានបញ្ហាពុំពេញចិត្តនឹងការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជននោះ ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចលើបណ្តឹងតវ៉ា ឬជំទាស់នោះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នោះជាការត្រឹមត្រូវ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ការឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ចុះឈ្មោះអ្នកដែលមានបញ្ហានោះក្នុងបញ្ជីបោះឆ្នោត តាមលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥៤ថ្មី(ពីរ) ២ នៃច្បាប់នេះ ឬលុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

ប្រសិនបើអ្នកតវ៉ា ឬអ្នកជំទាស់ពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦៦_ថ្មី(ពីរ)**

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ា ឬជំទាស់នោះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេលដប់ ( ១០ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នោះជាការត្រឹមត្រូវ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ :

_ចេញសេចក្តីសម្រេចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬបដិសេធឈ្មោះអ្នកប្តឹងតវ៉ា ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហា ។

_ផ្ញើសេចក្តីចម្លងនៃសេចក្តីយល់ព្រម ឬបដិសេធនេះមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហា ។

ប្រសិនបើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ តម្រូវឱ្យចុះឈ្មោះអ្នកប្តឹងតវ៉ា ឬអ្នកដែលមានបញ្ហា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ការឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ចុះឈ្មោះជននោះ តាមលក្ខខ័ណ្ឌចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងមាត្រា ៥៤ថ្មី(ពីរ) ២ នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនោះមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៦៧_ថ្មី**

នៅពេលដែលបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានសម្រេចជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់បញ្ជូនបញ្ជីបោះឆ្នោតផ្លូវការក្នុងឆ្នាំនីមួយៗ ទៅសាលាឃុំ សង្កាត់ដើម្បីទុកជាឯកសារផ្លូវការ ។

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិស្នើសុំពិនិត្យមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោតនេះបាន ។

គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ស្តីពីគណបក្សនយោបាយមានសិទ្ធិសុំបញ្ជីបោះឆ្នោតផ្លូវការថតចម្លងបានដោយបង់ថ្លៃ ។ តម្លៃត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

**មាត្រា ៦៨_ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតផ្លូវការនៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ នៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងទីស្នាក់ការគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត តាមកាលបរិច្ឆេទដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦៩_ថ្មី**

គណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាលជាតិនិងបរទេស អង្គការអន្តរជាតិ និងប្រទេសនានាអាចបញ្ជូនតំណាងរបស់ខ្លួនចូលសង្កេតការណ៍ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជារៀងរាល់ឆ្នាំ ។

តំណាងទាំងអស់ត្រូវមានការទទួលស្គាល់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៧

## ការឃោសនាបោះឆ្នោត

**មាត្រា ៧០_**

ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។

**មាត្រា ៧១_**

គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវជៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយឬបេក្ខជនដទៃទៀត ។

គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃឡើយ ។

**មាត្រា ៧២.-**

យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេលសាមសិប ( ៣០ ) ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវចប់ ២៤ ម៉ោង មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៧៣.-ថ្មី**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

របៀប បែបបទប្តឹងជំទាស់ ឬតវ៉ាក្នុងពេលឃោសនាបោះឆ្នោត និងការដោះស្រាយពាក្យបណ្តឹងត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចសេចក្តីចុងក្រោយ ។

**មាត្រា ៧៤.-**

គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមមានសារព័ត៌មាន វិទ្យុនិងទូរទស្សន៍របស់រដ្ឋត្រូវចុះផ្សាយគ្រប់ព័ត៌មានដែលស្នើដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយមិនយកថ្លៃ ដើម្បីផ្សព្វផ្សាយពីការងារបោះឆ្នោតនិងអប់រំដល់អ្នកបោះឆ្នោត ។

**មាត្រា ៧៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់វិធានការ ដើម្បីផ្សព្វផ្សាយអត្ថបទឃោសនាតាមសំណើរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ផ្អែកតាមគោលការណ៍ស្មើភាពនិងតាមលំដាប់ពេលមុនក្រោយ ។

**មាត្រា ៧៦.-**

ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គណបក្សនយោបាយនិងបេក្ខជនទាំងអស់មិនត្រូវប្រើអំពើហិង្សា អំពើរំលោភ សំដីប្រមាថមើលងាយ មិនត្រូវសាបព្រោះឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

**មាត្រា ៧៧.-**

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជនឬគណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់បម្រើការឃោសនាដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ ។

**មាត្រា ៧៨.-**

ក្នុងសម័យឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណបក្សនយោបាយឬបេក្ខជនដែលមានបំណងជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ដូចមានចែងក្នុងមាត្រា ៧៧ នៃច្បាប់នេះ ត្រូវធ្វើពាក្យសុំទៅអ្នកគ្រប់គ្រងទីកន្លែងទាំងនោះ បី ( ៣ ) ថ្ងៃយ៉ាងតិចមុនថ្ងៃប្រជុំឃោសនា ហើយត្រូវចម្លងពាក្យសុំនេះមួយច្បាប់ផ្ញើទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

អ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបនឹងពាក្យសុំជួលក្នុងរយៈពេលម្ភៃបួន ( ២៤ ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យសុំ ។

**មាត្រា ៧៩.-**

គណបក្សនយោបាយឬបេក្ខជនអាចធ្វើសកម្មភាពឃោសនានៅលើទីធ្លាឯកជន ឬនៅសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

**មាត្រា ៨០.-**

គណបក្សនយោបាយនិងបេក្ខជនទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

**មាត្រា ៨១.-**

ចំណាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយ និងរបស់បេក្ខជនម្នាក់ៗជាបន្ទុករបស់គណបក្សនយោបាយ ឬបេក្ខជនផ្ទាល់ ។

**មាត្រា ៨២.-**

គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនីដើម្បីកត់ប្រាក់ចំណូល ប្រភពនៃប្រាក់ចំណូលនិងចំណាយសម្រាប់ការឃោសនាបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចត្រួតពិនិត្យសៀវភៅគណនីនេះ នៅពេលមានការចាំបាច់ ។

**មាត្រា ៨៣.-**

វិភាគទានទាំងអស់ដែលគណបក្សនយោបាយបានទទួល ត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនាត្រូវតែចេញពីគណនីតែមួយនេះ ។

## ជំពូកទី ៨
## ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផល
## នៃការបោះឆ្នោត

**មាត្រា ៨៤_ថ្មី**

ការិយាល័យបោះឆ្នោតត្រូវរៀបចំតាមការកំណត់ដូចមានចែងក្នុងមាត្រា ៨៥ថ្មី និងមាត្រា ៨៦ថ្មី នៃច្បាប់នេះ ។

**មាត្រា ៨៥_ថ្មី**

ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោងប្រាំពីរ ( ៧:០០ ) ព្រឹក រហូតដល់ម៉ោង ដប់ប្រាំ ( ១៥:០០ ) លើកលែងតែមានសេចក្ដីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោតអាចប្រកាសបញ្ចប់ការបោះឆ្នោតមុនម៉ោងដប់ប្រាំ ( ១៥:០០ ) ។

ប្រធានការិយាល័យបោះឆ្នោតត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោងដប់ប្រាំ ( ១៥:០០ ) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណខាងក្នុងក្រោយម៉ោងដប់ប្រាំ (១៥:០០) ឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោងដប់ប្រាំ ( ១៥:០០ ) ហើយអាចអនុញ្ញាតឱ្យបោះឆ្នោត គឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោងដប់ប្រាំ (១៥:០០) ។

**មាត្រា ៨៦_**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយបញ្ជីឈ្មោះនិងទីតាំងការិយាល័យបោះឆ្នោត ហើយត្រូវបិទផ្សាយបញ្ជីទាំងនេះនៅគ្រប់ការិយាល័យបោះឆ្នោតសាមសិប ( ៣០ ) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ។

**មាត្រា ៨៧_**

គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតអាចសុំសេចក្ដីចម្លងនៃបញ្ជីឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនេះបានដោយបង់ថ្លៃ ។ តម្លៃនេះគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

**មាត្រា ៨៨_ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់ជូនការិយាល័យបោះឆ្នោតនីមួយៗនូវសម្ភារៈដូចតទៅ តាមចំនួនសមស្រប មួយថ្ងៃមុនថ្ងៃបោះឆ្នោត ៖

១_ បញ្ជីបោះឆ្នោត ។

២_ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។

៣_ ហិបឆ្នោត ។

៤_ បន្ទប់សម្ងាត់ ។
៥_ ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោត ។
៦_ ទឹកជ្រលក់សម្រាប់សម្គាល់ថាបានបោះឆ្នោតហើយ ។
៧_ សោ និងប្រដាប់ឃ្លុំ ។
៨_ ក្រដាសបែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។
៩_ ប៊ិចសរសេរដែលមានគុណភាពល្អ ។
១០_ ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។
១១_ ថង់ប្លាស្ទិក ។
១២_ សម្ភារៈ និងបរិក្ខារចាំបាច់ផ្សេងៗទៀត ។

**មាត្រា ៨៩_**

មុនថ្ងៃបោះឆ្នោតមួយថ្ងៃ ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវប្រជុំសមាជិកទាំងអស់ ដើម្បីត្រួតពិនិត្យវត្តមានសមាជិក និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារៈបរិក្ខារបំរើឱ្យការងារបោះឆ្នោត ។

ប្រសិនបើមានសមាជិកណាម្នាក់អវត្តមាន សមាជិកនោះត្រូវជំនួសដោយសមាជិកថ្មីដែលជ្រើសតាំងឡើងស្របតាមបទប្បញ្ញត្តិដែលចែងក្នុងបទបញ្ជា និងនីតិវិធី ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ការ ដើម្បីឱ្យការិយាល័យបោះឆ្នោតមានសម្ភារៈ បរិក្ខារ និងសង្ហារិមចាំបាច់សម្រាប់ការបោះឆ្នោត ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោត ហើយចាត់វិធានការការពារសន្តិសុខប្រសិនបើចាំបាច់ ។

**មាត្រា ៩០_**

នៅថ្ងៃបោះឆ្នោត សមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវមកដល់ទីតាំងការិយាល័យបោះឆ្នោតដើម្បីរៀបចំការបោះឆ្នោតមួយម៉ោងយ៉ាងតិច មុនចាប់ផ្តើមការបោះឆ្នោត ។

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មុននឹងអនុញ្ញាតឱ្យអ្នកទាំងនេះចូលក្នុងការិយាល័យបោះឆ្នោត ។

**មាត្រា ៩១_ថ្មី**

មុននឹងចាប់ផ្តើមការបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវបើកបង្ហាញហិបឆ្នោត នៅចំពោះមុខសមាជិកគណៈកម្មការ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ថា គ្មានអ្វីនៅក្នុងហិបឆ្នោតទេ រួចចាក់សោ និងកត់លេខឃ្លុំដែលចាក់នេះក្នុងកំណត់ហេតុនៃការបោះឆ្នោត បន្ទាប់មកត្រូវពិនិត្យ និងរាប់សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ដែលបានទទួលជាក់ស្តែង ព្រមទាំងបើកស្រោមសំបុត្រដែលមានត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

**មាត្រា ៩២-ថ្មី**

ប្រជាពលរដ្ឋម្នាក់ៗត្រូវបោះឆ្នោតតែនៅការិយាល័យបោះឆ្នោត ដែលឈ្មោះរបស់ខ្លួនមាននៅក្នុងបញ្ជីបោះឆ្នោត និងត្រូវមានឯកសារបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួន ។

**មាត្រា ៩៣-**

សមាជិកនៃគណៈកម្មការការិយាល័យបោះឆ្នោតត្រូវបានអញ្ជើញឱ្យបោះឆ្នោតមុនគេ បន្ទាប់មកតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតនោះ ។

**មាត្រា ៩៤-**

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតតែមួយសន្លឹកនិងតែមួយដងគត់ ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។

អ្នកបោះឆ្នោតម្នាក់ៗត្រូវបោះឱ្យគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្ត ដោយគូសសញ្ញាយកតែគណបក្សនយោបាយមួយ និងមិនត្រូវកែ ដូរឬបន្ថែមបន្ថយទេ ។ របៀបបោះឆ្នោតលំអិតផ្សេងទៀត ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៥-**

ការបោះឆ្នោតជាការសម្ងាត់របស់អ្នកបោះឆ្នោត ។

ការចង់ដឹងអំពីការសម្ងាត់ ឬការបង្ក្រើបការសម្ងាត់តាមរូបភាពណាក៏ដោយត្រូវហាមឃាត់ ។

**មាត្រា ៩៦-**

ដើម្បីរក្សារបៀបរៀបរយក្នុងបន្ទប់បោះឆ្នោត ជនម្នាក់ៗត្រូវគោរពតាមបទបញ្ជានៃការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៩៧-ថ្មី**

ចំពោះប្រជាពលរដ្ឋពិការដែលពុំអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនទៅជាមួយ ឬមានសិទ្ធិសុំជំនួយពីប្រធានការិយាល័យបោះឆ្នោត ។

**មាត្រា ៩៨-ថ្មី**

ប្រជាពលរដ្ឋដែលមានតែឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន តែពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោតពុំអាចបោះឆ្នោតបានឡើយ ។

**មាត្រា ៩៩-**

អាចចូលបានក្នុងការិយាល័យបោះឆ្នោតតែអ្នកត្រូវបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១០០.-**

ហាមដាច់ខាតមិនឱ្យយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខ នៃការិយាល័យបោះឆ្នោត និងហាមមិនឱ្យស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោតលើកលែងតែមានការអនុញ្ញាតពិសេសពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ទីធ្លាការិយាល័យបោះឆ្នោតត្រូវមានទំហំប្រមាណ ២ ០០០ ម៉ែត្រការ៉េ ហើយរង្វង់ការពារសន្តិសុខត្រូវស្ថិតនៅចំងាយប្រមាណ ២០០ ម៉ែត្រជុំវិញការិយាល័យបោះឆ្នោត លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១០១.-**

ក្នុងករណីដែលតំណាងគណបក្សនយោបាយបានយល់ឃើញថាការបោះឆ្នោតមិនប្រក្រតី តំណាងគណបក្សនយោបាយនោះអាចប្ដឹងជំទាស់ ឬតវ៉ាមកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតបាន ។

របៀបបែបបទប្ដឹងជំទាស់ឬតវ៉ា ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវដោះស្រាយបណ្ដឹងជំទាស់ ឬតវ៉ានេះ ។

ការសម្រេចរបស់គណៈកម្មការការិយាល័យបោះឆ្នោត ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ប្រសិនបើការបោះឆ្នោតនោះប្រព្រឹត្តទៅដោយប្រក្រតី ។

ប្រសិនបើអ្នកតំណាងនោះនៅតែជំទាស់ ឬតវ៉ា គណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះបណ្ដឹងជំទាស់ឬតវ៉ានេះក្នុងកំណត់ហេតុ ដោយឱ្យអ្នកជំទាស់ឬតវ៉ានោះចុះហត្ថលេខាជាមួយ ។

**មាត្រា ១០២.-**

ក្រោយពីការប្រកាសបញ្ចប់ការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះក្នុងកំណត់ហេតុនូវចំនួនអ្នកដែលបានមកបោះឆ្នោត និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើប្រាស់ហើយត្រូវរៀបចំដើម្បីរាប់សន្លឹកឆ្នោតនៅនឹងកន្លែងស្របតាមបទបញ្ជា និងនីតិវិធី ។

ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរៀបចំរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានសក្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងធ្វើការណែនាំដោយឡែក ។

អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិព្រមទាំងអ្នកតំណាងគណបក្សនយោបាយនីមួយៗអាចចូលរួមជាសាក្សីក្នុងការរាប់សន្លឹកឆ្នោតនេះ ។

**មាត្រា ១០៣.-**

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវទទួលខុសត្រូវរាប់សន្លឹកឆ្នោត ។ មុននឹងបើកហិបឆ្នោតប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវអញ្ជើញសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យ ឃ្លុំសោហើយបើកហិបឆ្នោតនៅចំពោះមុខអ្នកទាំងនោះ ។

**មាត្រា ១០៤_**

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវរាប់ចំនួនសន្លឹកឆ្នោត ដែលមាននៅក្នុងហិបឆ្នោតហើយផ្ទៀងផ្ទាត់ចំនួននេះ ជាមួយចំនួនអ្នកដែលបានមកបោះឆ្នោត ដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត ។

ក្នុងករណីដែលសន្លឹកឆ្នោតក្នុងហិបឆ្នោតមានចំនួនខុសគ្នានឹងចំនួនអ្នកបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ឱ្យរាប់ឡើងវិញ ។

ប្រសិនបើចំនួនខុសគ្នានៅតែមានដដែល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចុះក្នុងកំណត់ហេតុ ។

បន្ទាប់មកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ឱ្យរាប់សន្លឹកឆ្នោត ដោយអនុលោមបទបញ្ជា និងនីតិវិធី ។

**មាត្រា ១០៥_ថ្មី**

ត្រូវចាត់ទុកជាបានការ សន្លឹកឆ្នោតណាដែលមានគូសសញ្ញាគាំទ្រគណបក្សនយោបាយតែមួយនៅលើសន្លឹកឆ្នោតដែលគណៈកម្មការការិយាល័យបោះឆ្នោតចែកឱ្យ ។

ត្រូវទុកជាមោឃៈសន្លឹកឆ្នោត ៖

១_ ដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ ឬ

២_ ដែលគ្មានគំនូស ឬមានគំនូសតែគណៈកម្មការការិយាល័យបោះឆ្នោតពុំអាចសន្និដ្ឋានបានថាបោះឱ្យគណបក្សនយោបាយណាមួយ ឬ

៣_ ដែលមានសញ្ញាដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត ឬ

៤_ ដែលមានរហែក ឬខូច ។

៥_ ដែលគ្មានត្រាសម្ងាត់ជាផ្លូវការ ។

សន្លឹកឆ្នោតដែលទុកជាមោឃៈក្នុងចំណុចទី១ ទី២ ទី៣ ទី៤ ទី៥ ខាងលើនេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១០៦_**

បន្ទាប់ពីបានរាប់សន្លឹកឆ្នោតរួចហើយ គណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុអំពីការរាប់សន្លឹកឆ្នោតនេះជាពីរច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ បណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន និងឯកសារផ្សេងៗទៀត និងមួយច្បាប់ទៀតបិទនៅការិយាល័យបោះឆ្នោត ។

សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ា ឯកសារផ្សេងៗ ត្រូវច្រកដោយឡែកពីគ្នាក្នុងស្រោមសំបុត្រដែលបានចែកឱ្យ ។

កំណត់ហេតុស្តីពីការរាប់សន្លឹកឆ្នោតនេះ ត្រូវចុះហត្ថលេខាដោយប្រធាន និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ។ តំណាងគណបក្សនយោបាយអាចចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះបាន ។

**មាត្រា ១០៧_**

ការបញ្ជូន ការប្រគល់ និងការទទួលកំណត់ហេតុត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។

**មាត្រា ១០៨.-**

តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិអាចចូលរួមជាសាក្សីក្នុងការប្រគល់ ឬការទទួលកំណត់ហេតុបោះឆ្នោត ។

**មាត្រា ១០៩.-ថ្មី**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវប្រមូលកំណត់ហេតុ និងឯកសារទាំងអស់ពីគ្រប់គណៈកម្មការការិយាល័យបោះឆ្នោត រួចធ្វើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។ កំណត់ហេតុនេះ ត្រូវធ្វើជាបួនច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មួយច្បាប់ផ្ញើជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត មួយច្បាប់បិទផ្សាយនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងមួយច្បាប់ទៀតទុកជាឯកសារ ។

ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬពីភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតណាមួយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបើកការប្រជុំសម្រេចជាសាធារណៈជាបន្ទាន់ ។

ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតជាបន្ទាន់ ។

**មាត្រា ១១០.-**

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវប្រមូលកំណត់ហេតុទាំងអស់ពីគ្រប់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត រួចធ្វើកំណត់ហេតុសរុបពីលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងរបស់ខ្លួន ។ កំណត់ហេតុនេះត្រូវធ្វើជាបីច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយភ្ជាប់ទៅជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន ព្រមទាំងឯកសារផ្សេងៗទៀត មួយច្បាប់បិទនៅទីស្នាក់ការគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និងមួយច្បាប់ទៀតទុកជាឯកសារ ។

**មាត្រា ១១១.-ថ្មី**

ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬអំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវធ្វើសវនាការជាសាធារណៈ ដើម្បីសម្រេចអំពីបណ្តឹងតវ៉ាទាំងនោះជាបន្ទាន់ រួចហើយត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួន ភ្ជាប់ជាមួយនឹងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោត ជូនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬតំណាងត្រូវធ្វើការប្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាបន្ទាន់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការពិនិត្យ និងសម្រេចថាយកលទ្ធផលនៃការបោះឆ្នោតនេះជាបានការ ឬឱ្យបោះឆ្នោតសាជាថ្មី ។

ការបោះឆ្នោតសាជាថ្មីត្រូវធ្វើឡើងក្នុងរយៈពេលប្រាំបី ( ៨ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

**មាត្រា ១១២_ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រមូលលទ្ធផលទាំងអស់មកពិនិត្យហើយធ្វើការសម្រេចលើលទ្ធផលបោះឆ្នោត ។

បើភាពមិនប្រក្រតីមិនធ្ងន់ធ្ងរទេ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រកាសទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ។

ប្រសិនបើភាពមិនប្រក្រតីមានកម្រិតធ្ងន់ធ្ងរ ធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយជូនព័ត៌មានដល់គណបក្សនយោបាយ ។ ក្នុងករណីនេះ ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះត្រូវធ្វើប្រាំបី ( ៨ ) ថ្ងៃយ៉ាងយូរបន្ទាប់ពីការសម្រេចនេះ ។

**មាត្រា ១១៣_**

ក្រោយពីការត្រួតពិនិត្យនិងសម្រេចលើលទ្ធផលនៃការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

លទ្ធផលបណ្តោះអាសន្ននេះត្រូវធ្វើមួយច្បាប់ថ្វាយព្រះមហាក្សត្រ និងមួយច្បាប់ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ។ គណបក្សនយោបាយដែលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិសុំសេចក្តីចម្លងលទ្ធផលបណ្តោះអាសន្ននេះបាន ។

**មាត្រា ១១៤_**

បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្នក្នុងរយៈពេលចិតសិបពីរ ( ៧២ ) ម៉ោងយ៉ាងយូរ គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែកឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុសពីកាលបរិច្ឆេទ ដែលធ្វើខុសពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ។

**មាត្រា ១១៥_ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្តឹងតវ៉ា ក្នុងរយៈពេលសែសិបប្រាំបី ( ៤៨ ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចថា បណ្តឹងតវ៉ាពុំអាចទទួលបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។
- ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និង ទៅគណបក្សនយោបាយ ។

- ផ្តល់ព័ត៌មានទៅអ្នកប្តឹងតវ៉ា ឬ/និង គណបក្សនយោបាយថា អនុលោមតាមមាត្រា ១១៧ថ្មី នៃច្បាប់នេះ សាមីខ្លួន ឬគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលចិតសិបពីរ ( ៧២ ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងបដិសេធ ។
- ផ្ញើសេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ១១៦_ថ្មី**

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ថា បណ្តឹងតវ៉ាមានទឡ្ហីករណ៍សមហេតុសមផល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈដើម្បីសម្រេច ។ ក្នុងករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយកាលបរិច្ឆេទ ទីកន្លែងនៃសវនាការ ផ្តល់ព័ត៌មានទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងជូនព័ត៌មានទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

អ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយ និងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោត ឬ/និង គណៈកម្មការរៀបចំការបោះឆ្នោតដែលពាក់ព័ន្ធ ត្រូវមានវត្តមាននៅក្នុងសវនាការនេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ព្រមតាមពាក្យបណ្តឹង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- បដិសេធលទ្ធផលនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយរៀបចំឱ្យមានការបោះឆ្នោតសាជាថ្មីនៅកន្លែងនោះ ឬកន្លែងទាំងនោះ ក្នុងរយៈពេលប្រាំបី ( ៨ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។
- បំពេញបែបបទនៃការយល់ព្រមដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការយល់ព្រម។
- ផ្តល់សេចក្តីចម្លងនៃសេចក្តីយល់ព្រមមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និង គណបក្សនយោបាយ ។
- ផ្ញើសេចក្តីចម្លងនៃសេចក្តីយល់ព្រមមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំយល់ព្រមតាមបណ្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។
- ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធទៅអ្នកប្តឹងតវ៉ា ឬ/និង គណបក្សនយោបាយ ។
- ផ្តល់ព័ត៌មានដល់អ្នកប្តឹងតវ៉ា ឬ/និង គណបក្សនយោបាយថា អនុលោមតាមមាត្រា ១១៧ថ្មី នៃច្បាប់នេះ សាមីខ្លួន ឬគណបក្សនយោបាយនោះមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុម

ប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលចិតសិបពីរ ( ៧២ ) ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ ។

- ផ្ញើសេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ១១៧-ថ្មី**

ជនណា ឬ/និង គណបក្សនយោបាយណាដែលបណ្តឹងតវ៉ារបស់ខ្លួនត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬ/និងគណបក្សនយោបាយនោះមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលចិតសិបពីរ ( ៧២ ) ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីការបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបើកសវនាការជាសាធារណៈ សម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេលពី ដប់ ( ១០ ) ថ្ងៃទៅម្ភៃ ( ២០ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាការសម្រេចចុងក្រោយ ។

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថា បណ្តឹងតវ៉ាពុំអាចទទួលបាន ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

- បំពេញបែបបទនៃការបដិសេធដែលបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។
- ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- ផ្សព្វផ្សាយសេចក្តីសម្រេច និងទុកមួយច្បាប់ជាឯកសារ ។

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ថា បណ្តឹងតវ៉ាមានទឡ្ហីករណ៍សមហេតុសមផល ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបើកសវនាការជាសាធារណៈ ដើម្បីពិនិត្យ និងសម្រេចក្នុងរយៈពេលដប់ ( ១០ ) ថ្ងៃ ទៅម្ភៃ ( ២០ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

**ក.** ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

- បំពេញបែបបទនៃការយល់ព្រមដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការយល់ព្រម។
- ផ្តល់សេចក្តីចម្លងនៃការយល់ព្រមមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ ។
- ចេញសេចក្តីសម្រេចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅកន្លែងនោះ ឬនៅកន្លែងទាំងនោះក្នុងរយៈពេលប្រាំបី ( ៨ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។
- ផ្សព្វផ្សាយសេចក្តីសម្រេច និងរក្សាទុកមួយច្បាប់ជាឯកសារ ។

**ខ.** ក្នុងករណីដែលក្រុមប្រឹក្សាធម្មនុញ្ញពុំយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

- បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

- ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

- ផ្សព្វផ្សាយសេចក្តីបដិសេធ និងទុកមួយច្បាប់ជាឯកសារ ។

**មាត្រា ១១៨-ថ្មី**

**ក.** ក្រោយពីបណ្តឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ និងក្រោយពីបានទទួលលទ្ធផលនៃការបោះឆ្នោតទាំងអស់ រួមទាំងលទ្ធផលនៃការបោះឆ្នោតដែលត្រូវធ្វើសាជាថ្មី ប្រសិនបើមាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាផ្លូវការលទ្ធផលនៃការបោះឆ្នោត ហើយកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយនីមួយៗតាមមណ្ឌលនីមួយៗ ដោយគិតតាមចំនួនសន្លឹកឆ្នោតបានការ ។

ការបែងចែកអាសនៈតាមខេត្ត ក្រុង ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដោយផ្អែកលើចំនួនអាសនៈក្នុងខេត្ត ក្រុង និងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង តាមជំហានទាំងឡាយដូចខាងក្រោម៖

**ជំហានទី ១** : កំណត់ចំនួនកូតាដែលតម្រូវឱ្យគណបក្សនយោបាយណាមួយទទួលអាសនៈមួយ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបនៅក្នុងខេត្ត ក្រុង មកចែកនឹងចំនួនអាសនៈសរុបក្នុងខេត្ត ឬក្រុង តាមរូបមន្តដូចខាងក្រោមនេះ និងត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់ខេត្ត ក្រុងនីមួយៗ ៖

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}$$

ក្នុងនោះ ៖

- **$\text{ក}_{\text{ត}}$** : តាងឱ្យកូតាជាផលចែក ដោយមិនគិតសំណល់ចែក ។

- **$\text{ស}_{\text{ស}}$** : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង ។

- **$\text{អ}_{\text{ស}}$** : តាងឱ្យចំនួនអាសនៈសរុបតាមមណ្ឌលខេត្ត ក្រុង ។

**ជំហានទី ២** : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅក្នុងខេត្ត ក្រុង ។

រូបមន្តដូចខាងក្រោមត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់គណបក្សនយោបាយនីមួយៗ ដែលបានចូលរួមនៅក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង៖

$$\text{អ}_{\text{ឋ}} = \frac{\text{ស}_{\text{ប}}}{\text{ក}_{\text{ត}}}$$

ក្នុងនោះ ៖

- **$\text{អ}_{\text{ឋ}}$** : ជាផលចែកដោយមិនគិតសំណល់ចែក តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ មានសិទ្ធិបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣ ។

- **$ស_{ប}$** : តាងឱ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យគណបក្សនយោបាយណាមួយនៅក្នុងខេត្ត ក្រុង ។

- **$ក_{ធ}$** : តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីគណនា គ្រប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងខេត្ត ក្រុង ក្នុងជំហានទី ២ ប្រសិនបើគ្មានអាសនៈនៅសល់ ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈត្រូវសម្រេចកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង អាសនៈដែលនៅសល់ទាំងនេះត្រូវកំណត់ទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣** : អាសនៈដែលនៅសល់ ត្រូវបែងចែកឱ្យគណបក្សនយោបាយនីមួយៗមានសិទ្ធិបានទទួលនៅក្នុងខេត្ត ក្រុង ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត ។ រូបមន្តដូចខាងក្រោមត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់គណបក្សនយោបាយនីមួយៗ ដែលបានចូលរួមក្នុងការបោះឆ្នោតតាមខេត្ត ក្រុង ៖

$$ម_{ធ} = \frac{ស_{ប}}{អ_{ន}+១}$$

ក្នុងនោះ ៖

- **$ម_{ធ}$** : តាងឱ្យមធ្យមភាគខ្ពស់បំផុត ។

- **$ស_{ប}$** : តាងឱ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យគណបក្សនយោបាយមួយ ។

- **$អ_{ន}$** : តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យគណបក្សនយោបាយមួយ ។

ក្នុងករណីដែលនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទី ៣ សម្រាប់គណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីដែលនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី ៣ ហើយអាសនៈចំនួនមួយត្រូវបែងចែកទៅឱ្យគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត ។ បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ **$អ_{ន}$** ចំនួន ១ ចំពោះគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តរូបមន្តលើកទីមួយ ។ ដូច្នេះចំនួនអាសនៈចំនួនមួយត្រូវផ្តល់ឱ្យគណបក្សនយោបាយ ដែលមានមធ្យមភាគខ្ពស់បំផុត ក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈ ត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសនៈម្តងមួយអាសនៈជាបន្តបន្ទាប់ រហូតដល់អស់អាសនៈដែលនៅសល់ ។

**ខ.** ការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀងដូចមានចែងក្នុងមាត្រា ៣៨ថ្មី នៃច្បាប់នេះ ។

**គ.** ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពតំណាងរាស្ត្រ បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនោះត្រូវបានប្រកាសថាជាប់ឆ្នោតជាតំណាងរាស្ត្ររបស់សាមីគណបក្សនយោបាយ ។

**ឃ.** ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ដោយមូលហេតុដូចមានចែងក្នុងចំណុច **គ** នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលដប់បួន ( ១៤ ) ថ្ងៃក្រោយពីបានទទួលសំណើ ។

បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៣៣ថ្មី មាត្រា ៣៤ថ្មី មាត្រា ៣៥ថ្មី មាត្រា ៣៦ថ្មី មាត្រា ៣៨ថ្មី មាត្រា ៤១ថ្មី មាត្រា ៤២ថ្មី មាត្រា ៤៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬមិនបានកែលំអការខ្វះខាតដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

**ង.** ក្នុងករណីគណបក្សនយោបាយណាមួយបានទទួលអាសនៈមួយ ឬច្រើននៅក្នុងរដ្ឋសភា ប៉ុន្តែគណបក្សនយោបាយនោះបានប្រកាសបោះបង់ចោលអាសនៈរបស់ខ្លួន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយ តាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថាជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ ( ៧ ) ថ្ងៃ ទៅឱ្យគណបក្សនយោបាយផ្សេងដែលទទួលបានអាសនៈក្នុងខេត្ត ក្រុងជាមួយ តាមជំហានទាំងឡាយដូចខាងក្រោម ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់អាសនៈ ៖

**ជំហានទី ១** : កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួលមួយអាសនៈ តាមរូបមន្តដូចខាងក្រោម ៖

$$\text{ក'}_{\text{ត}} = \frac{\text{ស'}_{\text{ស}}}{\text{អ'}_{\text{ប}}}$$

ក្នុងនោះ ៖

- $\text{ក'}_{\text{ត}}$ : តាងឱ្យកូតាជាផលចែកដោយមិនគិតសំណល់ចែក ។

- $\text{ស}'_{\text{ស}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយទាំងអស់ដែលទទួលអាសនៈក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងខេត្ត ក្រុង ។

- $\text{អ}'_{\text{ប}}$ : តាងឱ្យអាសនៈដែលបានបោះបង់ចោលនៅក្នុងខេត្ត ក្រុង ។

**ជំហានទី ២** : កំណាត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលតាមរូបមន្តដូចខាងក្រោម ៖

$$\text{អ}'_{\text{ឆ}} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{ត}}}$$

ក្នុងនោះ ៖

- $\text{អ}'_{\text{ឆ}}$ : តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងខេត្ត ក្រុង បានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី ៣ ។

- $\text{ស}_{\text{ប}}$ : តាងឱ្យសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយមួយក្នុងខេត្ត ក្រុង ។

- $\text{ក}'_{\text{ត}}$ : តាងឱ្យចំនួនកូតាដែលបានកំណាត់ក្នុងជំហានទី ១ ។

បន្ទាប់ពីបានគណនាក្នុងជំហានទី ២ គ្រប់គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងខេត្ត ក្រុង លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសនៈក្នុងខេត្ត ក្រុង ក្នុងករណីគ្មាននៅសល់អាសនៈដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណាត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទី ២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណាត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣** : អាសនៈដែលនៅសល់ត្រូវបែងចែកដោយកំណាត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម ៖

$$\text{ម}'_{\text{ឆ}} = \frac{\text{ស}_{\text{ប}}}{\text{អ}'_{\text{ឆ}}+\text{១}}$$

ក្នុងនោះ ៖

- $\text{ម}'_{\text{ឆ}}$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត ។

- $\text{ស}_{\text{ប}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យគណបក្សនយោបាយមួយក្នុងខេត្ត ក្រុង ។

- $\text{អ}'_{\text{ឆ}}$ : តាងឱ្យចំនួនអាសនៈ ដែលបានបែងចែកឱ្យទៅគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងវាក្យខ័ណ្ឌទី៩ និងវាក្យខ័ណ្ឌទី១០ ចំណុច **ក** នៃមាត្រានេះ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី ៣ និងការគណនាជាបន្តបន្ទាប់ទៀត ។

ច. ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នាដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឱ្យគណបក្សណាមួយបាន អាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ឆ. ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុច ឃ នៃមាត្រានេះ ។

ជ. ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ក នៃមាត្រានេះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលនីមួយៗ ជាបន្តបន្ទាប់ ។

ឈ. មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើសេចក្តីរាយការណ៍ជូនគ្រប់តំណាងគណបក្សនយោបាយ ដែលចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ព ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ ។

**មាត្រា ១១៩.**

ការរាប់ចំនួនថ្ងៃតវ៉ានិងការសម្រេចលើបណ្តឹងតវ៉ា ដូចមានចែងក្នុងជំពូកទី៤ ជំពូកទី៦ និងជំពូកទី៨ នៃច្បាប់នេះ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

# ជំពូកទី ៩

## ករណីជ្រើសតាំងជំនួសសមាជិករដ្ឋសភា

**មាត្រា ១២០.-ថ្មី**

សមាជិករដ្ឋសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព ។
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។
- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ។
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិករដ្ឋសភារូបណាមួយត្រូវបាត់បង់សមាជិកភាពមានរយៈពេលប្រាំមួយ (៦) ខែយ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះ អាចស្នើជ្រើសតាំងសមាជិកថ្មីជំនួស ដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះ តាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ ។

## ជំពូកទី ១០
## ថវិកា

**មាត្រា ១២១.-**

ត្រូវបានបង្កើតគណនីពិសេសរបស់រតនាគារជាតិ ជាគណនីមូលនិធិទាយជ្ជទានការបោះឆ្នោតសម្រាប់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យកទៅចាត់ចែងក្នុងកិច្ចការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អនុលោមតាមច្បាប់ហិរញ្ញវត្ថុ ។

មូលនិធិទាយជ្ជទានការបោះឆ្នោតដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការក្រៅរដ្ឋាភិបាល និងចំណូលស្របច្បាប់ផ្សេងៗ ត្រូវបញ្ចូលក្នុងថវិកាជាតិ ដើម្បីផ្តល់ផ្ទាល់ឱ្យទៅគណនីពិសេសនេះ ។

ហិរញ្ញប្បទានក្រៅប្រទេសមួយចំនួន សម្រាប់ការបោះឆ្នោតអាចអនុវត្តដោយប្រតិបត្តិការក្រៅរតនាគារជាតិ ។

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

**មាត្រា ១២២.ថ្មី**

ត្រូវទទួលទណ្ឌកម្មរហូតបណ្តេញចេញពីការងារតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដោយពុំទាន់គិតដល់ទោស ព្រហ្មទណ្ឌផ្សេងទៀត ចំពោះស្មៀនឃុំ សង្កាត់ ឬមន្ត្រី ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាដែលប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

- បានចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមសរសេរឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតដោយចេតនា ។
- បានចុះឈ្មោះបោះឆ្នោតដោយចេតនាដល់អ្នកដែលពុំទាន់គ្រប់អាយុបោះឆ្នោត ឬដល់អ្នកដែលពុំបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់អាចបោះឆ្នោត ។
- បានចុះឈ្មោះ និងបានចេញបង្កាន់ដៃដោយចេតនាទៅអ្នកដែលត្រូវបានដកសិទ្ធិបោះឆ្នោត ។
- រារាំងប្រជាពលរដ្ឋដែលមានអាយុចាប់ពីដប់ប្រាំបី ( ១៨ ) ឆ្នាំឡើងទៅមិនឱ្យចុះឈ្មោះបោះឆ្នោត ។

**មាត្រា ១២៣.ថ្មី**

ត្រូវបដិសេធពាក្យស្នើសុំឈរឈ្មោះបោះឆ្នោតរបស់សាមីខ្លួន ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ថ្មី ឬមាត្រា ៣៤ថ្មី នៃច្បាប់នេះ ។

**មាត្រា ១២៤.ថ្មី**

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និងត្រូវផ្តន្ទាទោស

ពិន័យជាប្រាក់ពីប្រាំលាន ( ៥.០០០.០០០ ) រៀល ទៅ ម្ភៃប្រាំលាន ( ២៥.០០០.០០០ ) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា និងគណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។
- ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។
- ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។
- ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។
- រារាំងបេក្ខជននិងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។
- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន ។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន ។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។
- ទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាស ។

## មាត្រា ១២៥_ថ្មី

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន ( ១០.០០០.០០០ ) រៀល ទៅ ម្ភៃប្រាំលាន ( ២៥.០០០.០០០ ) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និង លុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ ( ៥ ) ឆ្នាំ ចំពោះសមាជិកគណៈកម្មាធិការជាតិ សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

## មាត្រា ១២៦_ថ្មី

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន ( ១០.០០០.០០០ ) រៀល ដល់ ហាសិបលាន ( ៥០.០០០.០០០ ) រៀល និងត្រូវបញ្ឈប់ពីការងារបោះឆ្នោតជារៀងរហូត ចំពោះភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិ ឬភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតណាដែលប្រព្រឹត្តល្មើសនឹងវាក្យខណ្ឌទី ២ មាត្រា ១២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## មាត្រា ១២៧_ថ្មី

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៥ថ្មី ឬមាត្រា ១០០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងករណីដែលមិនព្រមអនុវត្តតាមការព្រមាននេះ ត្រូវឃាត់ខ្លួន និង

ដកហូតអាវុធសម្រាប់រយៈពេលសែសិបប្រាំបី ( ៤៨ ) ម៉ោងដោយភ្នាក់ងារមានសមត្ថកិច្ច និងផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន ( ១០.០០០.០០០ ) រៀល ដល់ហាសិបលាន ( ៥០.០០០.០០០ ) រៀល ។

ប្រសិនបើជនល្មើសនោះជាមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ដើម្បីឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែង យោលទៅតាមកម្រិតនៃបទល្មើស ។
- លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាសមាជិក ឬជាបុគ្គលិករបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារភ្លាម និងមិនឱ្យចូលបំរើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សម្រាប់រយៈពេលដប់ ( ១០ ) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រានេះ ។

**មាត្រា ១២៨-ថ្មី**

គណៈកម្មាធិកាជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ ( ៥ ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៩ថ្មី នៃច្បាប់នេះ ។

**មាត្រា ១២៩-ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន ( ៥.០០០.០០០ ) រៀល ដល់ដប់លាន ( ១០.០០០.០០០ ) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ ( ៥ ) ឆ្នាំ ចំពោះជនណាដែលបង្ខាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបំរើការងារក្នុងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ ( ១០ ) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនប្រព្រឹត្តល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៣០-ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន ( ១០.០០០.០០០ ) រៀល ទៅម្ភៃប្រាំលាន ( ២៥.០០០.០០០) រៀល ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ប្រាំ ( ៥ ) ឆ្នាំ ចំពោះជនណាដែលមានចេតនាធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបំរើការងារជាមួយគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនល្មើសនោះជាបេក្ខជនវិញ ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៣១-ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន ( ៥.០០០.០០០ ) រៀល ទៅដប់លាន ( ១០.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬនិងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ ( ៥ ) ឆ្នាំ ចំពោះជនណា ឬគណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ថ្មី ឬមាត្រា ៧៦ នៃច្បាប់នេះ ។

**មាត្រា ១៣២-ថ្មី**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៧ ឬវាក្យខ័ណ្ឌទី ២ នៃមាត្រា ៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ក្នុងករណីដែលនៅតែពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ ( ៥ ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់បណ្តេញចេញពីមុខតំណែង ឬ/និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន ( ១.០០០.០០០ ) រៀល ដល់ពីរលាន (២.០០០.០០០) រៀល ។

**មាត្រា ១៣៣-ថ្មី**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧២ នៃច្បាប់នេះ ។ ក្នុងករណីដែលនៅពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ ( ៥ )ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន ( ៥.០០០.០០០ ) រៀល ដល់ដប់លាន (១០.០០០.០០០) រៀល ។

## ជំពូកទី ១២

## អន្តរប្បញ្ញត្តិ

**មាត្រា ១៣៤-ថ្មី**

ក្រោយពីច្បាប់នេះចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ដើម្បីពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវយកបញ្ជីបោះឆ្នោតចុងក្រោយដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កាលពីថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ធ្វើជាមូលដ្ឋាន ។

**មាត្រា ១៣៥-ថ្មី**

ក្រោយពីច្បាប់នេះចូលជាធរមាន ត្រូវយកការិយាល័យបោះឆ្នោតដែលបានបង្កើតឡើងសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលពីថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ធ្វើការជាការិយាល័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ នាថ្ងៃអាទិត្យ ទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ។

ក្នុងករណីដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើការកែសម្រួលការិយាល័យបោះឆ្នោត ឬង្កើតការិយាល័យបោះឆ្នោតថ្មី ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៩៥ថ្មី មាត្រា ៩៦ថ្មី **ក** និង **ខ** នៃច្បាប់នេះ និងត្រូវផ្សព្វផ្សាយជាសាធារណៈនូវការិយាល័យបោះឆ្នោតដែលបានកែសម្រួល ឬដែលបានបង្កើតថ្មីនេះយ៉ាងតិចសាមសិប ( ៣០ ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

**មាត្រា ១៣៦-ថ្មី**

**ក.** ដើម្បីពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ នេះ ប្រជាពលរដ្ឋដែលមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ឬផ្លាស់ប្តូរទីលំនៅ ប្រជាពលរដ្ឋនោះត្រូវទៅបង្ហាញខ្លួនដោយខ្លួនឯងផ្ទាល់នៅសាលាឃុំ សង្កាត់ ឬទីកន្លែងណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅ តាមកាលបរិច្ឆេទកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោតតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចធ្វើការកែសម្រួលរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៤៩ថ្មី នៃច្បាប់នេះ និងត្រូវបញ្ជូនបុគ្គលិក និងចាត់ត្រូវចាត់គ្រប់វិធានការជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ ដើម្បីអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិ ទី៣ នេះ ។

**ខ.** ក្រោយពីច្បាប់នេះចូលជាធរមាន ដើម្បីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ប្រជាពលរដ្ឋត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ប័ណ្ណបោះឆ្នោត ឬវិញ្ញាបនបត្រជំនួសប័ណ្ណបោះឆ្នោតដែលមានស្រាប់ សម្រាប់ធ្វើជាឯកសារក្នុងពេលចុះឈ្មោះបោះឆ្នោត និងពេលបោះឆ្នោតបន្ថែមពីលើឯកសារ ដូចដែលបានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥០ថ្មី មាត្រា ៥៤ថ្មី ចំណុច **ក ខ គ ឃ ង** នៃច្បាប់នេះ តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតលើមូលដ្ឋាននៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ជនណាក៏ដោយក៏មានសិទ្ធិប្តឹងជំទាស់ចំពោះអ្នកដែលមានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនបត្រជំនួសប័ណ្ណបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៅពេលដែលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អ្នកដែលមានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនបត្រជំនួសប័ណ្ណបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះពុំមានលក្ខណសម្បត្តិត្រឹមត្រូវគ្រប់គ្រាន់តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៥០ថ្មី មាត្រា ៥៤ថ្មី **ក ខ គ ឃ** និង **ង** នៃច្បាប់នេះ ។

ការប្តឹងជំទាស់ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៦៤ថ្មី មាត្រា ៦៥ថ្មី និង មាត្រា ៦៦ថ្មី នៃច្បាប់នេះ ។

**មាត្រា ១៣៧-ថ្មី**

ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃអាទិត្យទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ការរាប់សន្លឹកឆ្នោតដូចមានចែងក្នុងមាត្រា ១០២ មាត្រា ១០៣ មាត្រា ១០៤ និងមាត្រា ១០៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត នៃព្រះរាជាណាចក្រកម្ពុជា ឬទីកន្លែងណាមួយដែលមានសុវត្ថិភាពតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបទបញ្ជា នីតិវិធីលំអិតនៃការដឹកជញ្ជូនហិបឆ្នោត ការរាប់សន្លឹកឆ្នោត ដើម្បីធានាឱ្យការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយតម្លាភាព មានសុវត្ថិភាព គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ និងធានាឱ្យបាននូវលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតឃើញច្បាស់នូវសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

**មាត្រា ១៣៨-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៣៩-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១** **នាយករដ្ឋមន្ត្រីទី២**

**អ៊ឹង ហួត** **ហ៊ុន សែន**

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ខេង** **យូ ហុកគ្រី**

មាត្រា៣៖-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី១៧ខែកញ្ញាឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

នស/រកម/០៩០២/០៣៥ ហត្ថលេខា និង ត្រា

ជា ស៊ីម

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ: ១៩៣ ចល

ដើម្បីចម្លងចែក

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង យូ ហុកគ្រី

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

**មាត្រា២៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦

ចាស.០៦០៦.២៩៣ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង**

លេខ : ២៧២៦.ល

...ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**មាត្រាពីរ.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី៣១ ខែមករា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៧០១.០៤៥ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខៈ ៧០ ច.ល
**ដើម្បីចម្លងចែក**
**រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៧**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**យុន ជិនកេន**

**មាត្រា ពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១១

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៧១១/៥៥៣

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខៈ ៧០៥ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១១
**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# លិបិក្រម

## ចំណងជើង និងមាត្រាយោង

### ការចុះឈ្មោះបោះឆ្នោត

- លក្ខខណ្ឌនៃការចុះឈ្មោះបោះឆ្នោត (ម.៥០ថ្មី និង ម.៥៤ថ្មី)
- រយៈពេលបន្ថែមនៃការចុះឈ្មោះ (ម.៤៩ថ្មី)

### ការចំណាយសម្រាប់ការបោះឆ្នោត

- ប្រាក់កម្រៃសំរាប់សមាជិក និងបុគ្គលិក គ.ជ.ប (ម.៣១)
- ការថតចម្លង តារាងឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោត (ម.៤៧ថ្មី និងម.៨៧)
- ការថតចម្លងបញ្ជីឈ្មោះបោះឆ្នោត (ម.៦៣ថ្មី)
- បន្ទុកនៃការឃោសនាបោះឆ្នោត (ម.៨១ ម.៨២ និងម.៨៣)
- គណនីមូលនិធិទាយជ្ជទាន (ម.១២១)

### ការបោះឆ្នោតសាជាថ្មី

- ម.១១១ថ្មី ម.១១២ថ្មី ម.១១៦ និងម.១១៧ថ្មី

### ការដកហូតសិទ្ធិបោះឆ្នោត

- ម.១៦ថ្មី វ.១៦ ម.៣៣ និងម.៥៤

### ការឃោសនាបោះឆ្នោត

- គោលបំណង និងគោលការណ៍នៃការឃោសនាបោះឆ្នោត ម.៧០ ម.៧៣ថ្មី ម.៧៥ ម.៧៦ និង ម.៧៧
- សមត្ថកិច្ចត្រួតពិនិត្យការឃោសនា និងផ្សព្វផ្សាយព័ត៌មាន (ម.១៦ថ្មី)
- រយៈពេលនៃយុទ្ធនាការឃោសនា (ម.៧២)
- ទីកន្លែងឃោសនាបោះឆ្នោត (ម.៧៧ ម.៧៨ ម.៧៩ និងម.១៣២ថ្មី)
- បន្ទុកនៃយុទ្ធនាការឃោសនា (ម.៨០)
- គណនីចំណូល ចំណាយគណបក្សនយោបាយ (ម.៨១ ម.៨២ និងម.៨៣)

## ការប្រគល់សិទ្ធិ

- ពីប្រធាន គ.ជ.ប ទៅសមាជិកដទៃទៀត (ម.១៧ថ្មី)
- ពី គ.ជ.ប ទៅស្ថាប័នក្រោមបង្គាប់ (ម.២៤)

## ការផ្សព្វផ្សាយ

- សមត្ថកិច្ចត្រួតពិនិត្យការផ្សព្វផ្សាយ (ម.១៦ថ្មី)
- ការកំណត់ចំនួនអាសនៈអ្នកតំណាងរាស្ត្រ (ម.៨)
- ការផ្សព្វផ្សាយការងារបោះឆ្នោត និងអបរំ(ម.៧៤)
- ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត (ម.៤៤)
- ការបិទផ្សាយបញ្ជីការិយាល័យបោះឆ្នោត (ម.៤៧ថ្មី)
- ការបិទផ្សាយបញ្ជីបោះឆ្នោតតំបូង (ម.៦៣ថ្មី)
- ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការនៅមូលដ្ឋាន (ម.៦៨ថ្មី)
- ការផ្សព្វផ្សាយអត្ថបទឃោសនា (ម.៧៥)
- ការផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន (ម.១១៣)
- ការផ្សព្វផ្សាយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ម.១១៧ថ្មី)
- ការផ្សព្វផ្សាយលទ្ធផលបោះឆ្នោតស្ថាពរ និងបែងចែកអាសនៈ (ម.១១៨ថ្មី)

## ការិយាល័យបោះឆ្នោត

- ការិយាល័យតែមួយ ឈ្មោះអ្នកបោះឆ្នោតតែមួយ (ម.៤៧ថ្មី)
- ទីតាំងការិយាល័យបោះឆ្នោត (ម.១៦ថ្មី ម.៤៥ថ្មី ម.៤៦ថ្មី ម.៤៨ ម.៨៤ ម.៨៥ ម.៩០ ម.៩២ ថ្មី ម.៩៣ ម.៩៩ ម.១០០ ម.១១២ថ្មី ម.១១៦ និងម.១៣៥ថ្មី)
- ការបិទផ្សាយឈ្មោះ និងទីតាំងការិយាល័យជាសាធារណៈ (ម.៤៧ថ្មី ម.៨៦)
- សម្ភារៈសម្រាប់ដំណើរការបោះឆ្នោត (ម.១៦ថ្មី ម.៨៥ថ្មី ម.៨៨ថ្មី ម.៨៩ ម.៩០ ម.៩១ថ្មី ម. ៩២ថ្មី ម.៩៣ ម.៩៩ និងម.១១២)

## កាលបរិច្ឆេទ និងថេរៈវេលាទាក់ទងនឹងដំណើរការបោះឆ្នោត

- កាលបរិច្ឆេទរៀបចំការបោះឆ្នោត ករណីរដ្ឋសភារំលាយមុនអាណត្តិ (ម.១៤)

- ការកំណត់ពេលវេលាបោះឆ្នោត (ម.៣ថ្មី និងម.៨៥ថ្មី)
- ការផ្សព្វផ្សាយការិយាល័យបោះឆ្នោត (ម.៨៦ ម.៨៩ ម.៩០ និងម.១៣៥ថ្មី)
- ការចុះបញ្ជីគណបក្សនយោបាយ (ម.៣៧ថ្មី ម.៤០ថ្មី ម.៤១ថ្មី ម.៤២ថ្មី និងម.៤៣ថ្មី)
- ដំណាក់កាលចុះឈ្មោះអ្នកបោះឆ្នោត (ម.៥៦ថ្មី ម.៥៧ថ្មី ម.៥៨ថ្មី ម.៥៩ថ្មី ម.៦០ថ្មី ម.៦១ថ្មី ម.៦២ថ្មី ម.៦៣ថ្មី ម.៦៤ថ្មី ម.៦៥ថ្មី និងម.៦៦ថ្មី)
- សុពលភាពនៃបញ្ជីឈ្មោះបោះឆ្នោត (ម.៤៨ថ្មី ម.៤៩ថ្មី)
- ការឃោសនាបោះឆ្នោត (ម.៧២ ម.៧៨)
- ដំណាក់កាលរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល (ម.១១២ថ្មី ម.១១៤ ម.១១៥ថ្មី ម.១១៦ថ្មី ម.១១៧ថ្មី)
- អាណត្តិការងារនៃស្ថាប័នបំរើការបោះឆ្នោត (ម.៣២ថ្មី)

## ការលាលែងតំណែងពីស្ថាប័នដើម

- ម.១៥ថ្មី

កំណាត់ហេតុ

- ម.១០១ ម.១០២ ម.១០៤ ម.១០៦ ម.១០៧ ម.១០៨ ម.១០៩ ម.១១០ ម.១១១ថ្មី និងម.១១៥ថ្មី

ក្រុមប្រឹក្សាឃុំ សង្កាត់

- ប្រតិភូកម្មរបស់ គ.ជ.ប (ម.៥៣ថ្មី)
- ការិយាល័យបោះឆ្នោត/ដែលដីរដ្ឋបាលឃុំ សង្កាត់ (ម.៤៥ថ្មី ម.៤៦ថ្មី ម៥៥ថ្មី និងម.៦៧ថ្មី)
- តួនាទីក្រុមប្រឹក្សាឃុំ សង្កាត់ (ម.៣៨ថ្មី ម.៥៦ថ្មី ម.៦១ថ្មី និងម.៦៣ថ្មី)
- ការរក្សាបញ្ជី និងសៀវភៅបញ្ជីបោះឆ្នោត (ម.៤៨ថ្មី ម.៤៩ថ្មី និងម.៦៧ថ្មី)
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ (ម.១៦ វ.១០ ម.៥៣ថ្មី ម.៥៤ថ្មី ម.៥៥ថ្មី និងម.៥៦ថ្មី)
- សវនាការក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះបណ្ដឹងទៅនឹងបញ្ជីឈ្មោះបោះឆ្នោតតំបូង (ម.៦៤ថ្មី ម.៦៥ថ្មី

- ទណ្ឌកម្ម (ម.១២២ថ្មី ម.១២៧ថ្មី និងម.១៣០ថ្មី)

ក្រុមប្រឹក្សាធម្មនុញ្ញ

- គោលការណ៍នៃសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ម.៤៣)
- តួនាទីក្នុងការដោះស្រាយវិវាទទាក់ទងការ និងដំណើរការបោះឆ្នោត (ម.៤១ថ្មី ម.៤២ថ្មី ម.៦១ថ្មី ម.៦២ថ្មី ម.៦៥ថ្មី ម.៦៦ថ្មី ម.៧៣ ម.១១៣ ម.១១៤ ម.១១៥ថ្មី ម.១១៦ថ្មី និងម.១១៧ថ្មី)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

- ចរិតលក្ខណៈរបស់ គ.ជ.ប (ម.១២)
- សមត្ថកិច្ចរៀបចំការបោះឆ្នោត (ម.៤ ម.១១)
- រចនាសម្ព័ន្ធ គ.ជ.ប (ម.១១)
- សមាសភាពរបស់ គ.ជ.ប (ម.១៣ថ្មី)
- អគ្គលេខាធិការដ្ឋាន គ.ជ.ប (ម.៣០ ម.៣១)
- ឋានៈ បុព្វសិទ្ធិ និងតួនាទីនៃសមាជិក គ.ជ.ប (ម.៣០ ម.១៧ថ្មី)
- ការបាត់បង់តំណែងជាសមាជិក គ.ជ.ប (ម.១៥ថ្មី)
- វិសមិតភាពជាសមាជិក គ.ជ.ប (ម.១៥ ម.២៥ ម.៣៣ថ្មី និងម.៣៤ថ្មី)
- សិទ្ធិ អំណាច និងតួនាទីរបស់ គ.ជ.ប (ម.១៣ថ្មី ម.១៥ថ្មី ម.១៦ថ្មី ម.១៨ថ្មី ម.២៨ ម.៣៧ថ្មី ម.៤៥ថ្មី ម.៤៦ថ្មី ម.៤៧ថ្មី ម.៤៩ថ្មី ម.៥០ថ្មី ម.៥១ថ្មី ម.៥៤ថ្មី ម.៥៥ថ្មី ម.៥៩ថ្មី ម.៦៧ថ្មី ម.៦៨ថ្មី ម.៦៩ថ្មី ម.៧៣ថ្មី ម.៧៥ ម.៨២ ម.៨៥ថ្មី ម.៩៤ ម.៩៥ ម.៩៦ ម.៩៩ ម.១០០ ម.១០៥ថ្មី ម.១១០ ម.១១២ថ្មី ម.១១៨ថ្មី ម.១២៤ថ្មី ម.១៣៦ថ្មី និងម.១៣៧ថ្មី)
- ការទទួលស្គាល់អ្នកសង្កេតការណ៍បោះឆ្នោត (ម.២៨)
- ការត្រួតពិនិត្យគណនីគណបក្សនយោបាយ (ម.១៦ថ្មី ម.៨២)
- ការផ្គត់ផ្គង់សំភារៈទាក់ទងទៅនឹងការបោះឆ្នោត (ម.៨៨)
- ការបដិសេធចំពោះបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនគណបក្សនយោបាយ (ម.៤១ថ្មី ម.៤២ថ្មី)
- ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ (ម.៤៤)
- សុពលភាពបញ្ជីឈ្មោះបោះឆ្នោត (ម.៤៨ថ្មី ម.៤៩ថ្មី)
- ការផ្សព្វផ្សាយព័ត៌មាន (ម.៧៤ ម.៧៥ ម.៨៦ ម.១១៣ ម.១១៦ ម.១១៧ ម.១១៨ថ្មី)

- តួនាទីក្នុងការដោះស្រាយវិវាទទាក់ទងការបោះឆ្នោត (ម.៦០ ម.៦១ថ្មី ម.៦២ថ្មី ម.៦៥ថ្មី ម.១១១ ម.១១៤ ម.១១៥ថ្មី ម.១១៦ថ្មី ម.១១៧ថ្មី ម.១៣៦ថ្មី)
- កូរ៉ុមនៃការប្រជុំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ម.១៧ថ្មី)
- អាណត្តិការងាររបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ម.៣២ថ្មី)
- ទណ្ឌកម្ម (ម.១២៥ថ្មី ម.១២៧ថ្មី ម.១២៩ថ្មី និងម.១៣០)

## គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

- ចរិតលក្ខណៈរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (ម.១២)
- ការតែងតាំងសមាសភាព (ម.១៦ថ្មី វ.៣ ម.១៨ថ្មី)
- វិសមិតភាពជាសមាជិក (ម.១៨ថ្មី ម.២៥ ម.៣៤ថ្មី)
- ការបាត់បង់តំណែងក្នុងសមាសភាព (ម.១៥ថ្មី)
- លេខាធិការដ្ឋាន (ម.១៨ថ្មី)
- អាណត្តិការងារ (ម.៣២ថ្មី)
- ភារកិច្ច និងការទទួលខុសត្រូវ (ម.១៩ ម.២០ថ្មី ម.២២ថ្មី ម.២៤ ម.៥៦ថ្មី ម.៥៩ថ្មី ម.៦៨ ម.១០៩ និងម.១១០)
- តួនាទីក្នុងការដោះស្រាយវិវាទទាក់ទងការបោះឆ្នោត (ម.១១១ថ្មី)
- ទណ្ឌកម្ម (ម.១២៥ថ្មី ម.១២៧ថ្មី ម.១២៩ថ្មី និងម.១៣០)

## គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

- ចរិតលក្ខណៈរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (ម.១២)
- ការតែងតាំងសមាសភាព (ម.១៦ថ្មី វ.៣ ម.២០ថ្មី)
- វិសមតិភាពនៃសមាជិក (ម.២០ថ្មី ម.២៥ ម.៣៤ថ្មី)
- ការបាត់បង់តំណែងក្នុងសមាសភាព (ម.១៥ថ្មី)
- ភារកិច្ច និងការទទួលខុសត្រូវ (ម.២១ ម.២៤ ម.៦៨ថ្មី ម.៧៨ ម.៧៩ ម.៩១ថ្មី ម.១០៦ ម.១០៩ និងម.១៣៧ថ្មី)
- អាណត្តិការងារ (ម.៣២ថ្មី)
- ទណ្ឌកម្ម (ម.១២៥ថ្មី ម.១២៧ថ្មី ម.១២៩ថ្មី និងម.១៣០ថ្មី)

## គណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត

- ចរិតលក្ខណៈរបស់គណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត (ម.១២)
- សមាសភាព (ម.១៥ថ្មី ម.១៦ថ្មី វ.៣ ម.២២ថ្មី ម.៨៩ថ្មី ម.៩០ថ្មី ម.៩១ថ្មី ម.៩៣ ម.៩៧ថ្មី ម .១០៣ និងម.១០៦)
- វិសមតិភាពនៃសមាជិក (ម.២២ថ្មី ម.២៥ និងម.៣៤ថ្មី)
- ភារកិច្ច និងការទទួលខុសត្រូវ (ម.២៣ ម.២៤ ម.៦៨ថ្មី ម.៨៨ ម.៨៩ ម.៩០ ម.១០១ ម .១០២ ម.១០៣ ម.១០៤ ម.១០៥ ម.១០៦ និងម.១០៩)
- តួនាទីប្រធានគណៈកម្មការ (ម.៨៥ ម.៨៩ ម.៩១ថ្មី ម.៩៧ ម.១០១ ម.១០៣ ម.១០៤ និងម .១០៦)
- ទណ្ឌកម្ម (ម.១២៥ថ្មី ម.១២៧ថ្មី ម.១២៩ថ្មីនិង១៣០ថ្មី)

## គណបក្សនយោបាយ

- អ្នកតំណាងគណបក្សនយោបាយ (ម.១៦ថ្មី វ.១៧ ម.២៦ថ្មី ម.៦៨ថ្មី ម.៩០ ម.៩១ថ្មី និង ម .៩៣)
- រយៈពេលបើកបញ្ជី និងទម្រង់បែបបទចុះឈ្មោះគណបក្សនយោបាយ (ម.១៦ថ្មី វ.១៣ វ.១៤ ម .៣៧ថ្មី ម.៣៨ថ្មី ម.៣៩ និងម.៤០ថ្មី)
- ការឃោសនាបោះឆ្នោត (ម.១៦ថ្មី វ.១៧ ម.៧០ ម.៧៣ថ្មី ម.៧៥ ម.៨១ ម.៨២ និងម.៨៣)
- ប្រការហាមឃាត់នៅពេលឃោនាបោះឆ្នោត (ម.៧១ ម.៧៦ និងម.៨០)
- ប្រការហាមឃាត់ផ្សេងៗទៀត (ម.១២៤ថ្មី)
- ទីកន្លែងឃោសនាបោះឆ្នោត (ម.៧៧ ម.៧៨ និងម.៧៩)
- ការថតចម្លងឯកសារ (ម.៤៧ថ្មី ម.៦៧ថ្មី ម.៨៧ និងម.១១៣)
- សន្លឹកឆ្នោត (ម.៩៤ ម.១០៥ថ្មី និងម.១១២ថ្មី
- ការធ្វើបណ្តឹង (ម.៤២ថ្មី ម.១០៥ថ្មី និងម.១១២ថ្មី)
- រូបមន្តកំណត់កូតានៃអាសនៈ (ម.១១៨ថ្មី)
- ការតែងតាំងសមាជិករដ្ឋសភា (ម.១២០ថ្មី)
- ទណ្ឌកម្ម (ម.១២៤ថ្មី ម.១៣០ថ្មី ម.១៣១ និងម.១៣៣)

## គោលការណ៍នៃការបោះឆ្នោត

- លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស (ម.២)
- ជាសកល ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ដោយស្មើភាព ដោយចំពោះ និងជាសម្ងាត់ (ម.៥ ម.១៦ថ្មី វ.១ ម.៧៤ ម.៧៦ ម.៧៧ ម.៩៥ ម.១០៥ថ្មី និងម.១៣៧ថ្មី)

## គោលការណ៍នៃសវនាការ (សាធារណភាពនៃសវនាការ)

- ម.៦៥ថ្មី ម.៦៦ថ្មី ម.១១១ថ្មី ម.១១៦ និងម.១១៧ថ្មី

## ជនពិការ

- ម.៩៧ថ្មី ម.១៣០ថ្មី

## បញ្ជីឈ្មោះអ្នកបោះឆ្នោត

- បញ្ជីបោះឆ្នោត (ម.៥៣ថ្មី ម.៥៤ថ្មី ម.៨៥ថ្មី ម.៨៨ថ្មី ម.៩២ថ្មី ម.១០៤ ម.១០៦ និងម.១២៤ថ្មី)
- ការរក្សាទុកបញ្ជីឈ្មោះអ្នកបោះឆ្នោត (ម.៤៨ថ្មី ម.៤៩ថ្មី)
- ចំនួនអ្នកបោះឆ្នោតអតិបរមាសម្រាប់ការិយាល័យនិមួយៗ (ម.៤៦ថ្មី)
- សុពលភាពនៃបញ្ជីចុងក្រោយ (ម.៤៨ថ្មី ម.៤៩ថ្មី និងម.១៣៤ថ្មី)
- ការបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោត (ម.៦៣ថ្មី ម.៦៨ថ្មី)
- គោលការណ៍នៃឈ្មោះតែមួយនៅក្នុងបញ្ជី (ម.៥២ថ្មី)
- ការតវ៉ា ឬជំទាស់ទៅនឹងគល់បញ្ជីបោះឆ្នោត (ម.១៦ថ្មី វ.២៥ ម.៥៦ថ្មី ម.៥៧ថ្មី ម.៥៨ថ្មី ម.៥៩ថ្មី ម.៦០ថ្មី ម.៦៤ថ្មី ម.៦៥ថ្មី ម.៦៦ថ្មី ម.៧៣ថ្មី និងម.១៣៦ថ្មី)
- ការផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកបោះឆ្នោត និងសន្លឹកឆ្នោត (ម.១០៤)

## បេក្ខជនឈរឈ្មោះបោះឆ្នោត

- លក្ខខណ្ឌនៃការឈរឈ្មោះ (ម.១៦ថ្មី វ.១៦ ម.៣៣ថ្មី ម.៣៧ថ្មី និងម.៣៨ថ្មី)
- វិសមតិភាពក្នុងការឈរឈ្មោះ (ម.២៥ ម.៣៤ថ្មី ម.៣៥ថ្មី និងម.៣៦ថ្មី)
- ការលាលែងពីស្ថាប័នដើម (ម.១៥ថ្មី ម.៣៩ថ្មី)

- បែបបទនៃការចុះឈ្មោះបេក្ខជន (ម.៣៨ថ្មី)
- ការអនុគ្រោះចំពោះសហព័ទ្ធ និងកូន (ម.៥១ថ្មី)
- ការឃោសនាបោះឆ្នោត (ម.៧០ ម.៧១ និងម.៨១)
- ប្រការហាមឃាត់ក្នុងពេលឃោសនា (ម.៧១ ម.៧៦ និងម.៨០)
- ទីកន្លែងឃោសនាបោះឆ្នោត (ម.៧៧ ម.៧៨ និងម.៧៩)
- អាសនៈអ្នកតំណាងរាស្ត្រ (ម.១១៨ថ្មី)
- ទណ្ឌកម្ម (ម.៣៩ថ្មី ម.១២៣ថ្មី ម.១២៤ថ្មី ម.១២៩ថ្មី ម.១៣០ថ្មី ម.១៣១ និងម.១៣៣)

## បណ្ដឹង

- បណ្ដឹងតវ៉ាទៅនឹងការបដិសេធបេក្ខភាពឈរឈ្មោះបោះឆ្នោត (ម.១៦ថ្មី វ.២៥ ម.៤១ថ្មី និងម.៤២ថ្មី)
- បណ្ដឹងតវ៉ាទាក់ទងទៅនឹងការចុះឈ្មោះបោះឆ្នោត (ម.១៦ថ្មី វ.២៥ ម.៥៦ថ្មី ម.៥៧ថ្មី ម.៥៨ថ្មី ម.៥៩ថ្មី និងម.៦០ថ្មី)
- បណ្ដឹងតវ៉ា ឬជំទាស់នឹងបញ្ជីបោះឆ្នោតដំបូង (ម.១៦ថ្មី វ.២៥ ម.៦៤ថ្មី ម.៦៥ថ្មី ម.៦៦ថ្មី និងម.១៣៦ថ្មី)
- ការតវ៉ា ឬជំទាស់នៅដំណាក់កាលឃោសនាបោះឆ្នោត (ម.៧៣ថ្មី)
- ការតវ៉ាទៅនឹងភាពមិនប្រក្រតី ឬលទ្ធផលបោះឆ្នោត (ម.១៦ថ្មី វ.២៥ ម.១០១ ម.១០៦ ម.១១១ថ្មី ម.១១៥ថ្មី ម.១១៦ថ្មី ម.១១៧ថ្មី និង១១៨ថ្មី)
- ការរាប់អាជ្ញាយុកាលនៃបណ្ដឹង (ម.១១៩)

## ប្រព័ន្ធបោះឆ្នោត

- ប្រពន្ធ័សមាមាត្រ (ម.៥)

## ភូមិ

- ម.៤៦ថ្មី

មន្ត្រីសាធារណៈ (មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ ភ្នាក់ងារតុលាការ...)

- វិសមតិភាពមុខងារ (ម.១៥ថ្មី ម.១៨ថ្មី ម.២០ថ្មី ម.២២ថ្មី ម.៣៣ ម.៣៤ ម.៣៥ថ្មី ម.៥៤ និង ម.១០០)
- ទណ្ឌកម្ម (ម.១២៧ថ្មី ម.១២៨ថ្មី)

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- សេចក្តីព្រាងសមាសភាពនៃ គ.ជ.ប (ម.១៣ថ្មី ម.១៥ថ្មី)

## រដ្ឋសភា

- អាសនៈនៃអ្នកតំណាងរាស្ត្ររដ្ឋសភា (ម.៦ ម.៧ ម.៨ ម.៩ ម.១០ ម.៣៧ថ្មី ម.៤០ថ្មី និងម. ១១៨ថ្មី)
- ករណីរំលាយមុនអាណត្តិ (ម.៣ថ្មី ម.១៤ ម.៣៧ថ្មី ម.៤២ថ្មី ម.៤៨ថ្មី ម.៤៩ថ្មី)
- ការសម្រេចតែងតាំង និងការបណ្តេញចេញពីសមាសភាព គ.ជ.ប (ម.១៣ថ្មី  ម.១៥ថ្មី)
- ការបាត់បង់ពីសមាជិកភាពរដ្ឋសភា (ម.១២០ថ្មី)

## លទ្ធផលនៃការបោះឆ្នោត

- ម.១១០ ម.១១១ថ្មី ម.១១២ថ្មី ម.១១៣ ម.១១៤ ម.១១៦ថ្មី ម.១១៧ថ្មី និងម.១១៨ថ្មី

## សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ប្រធានសក្តិ

- សហប្រតិបត្តិការក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ (ម.៣ថ្មី ម.១៦ថ្មី វ.២៥ ម. ២៩ថ្មី ម.៨៩ និងម.១០២
- ការហាមឃាត់ផ្សេងៗ (ម.៥៥ថ្មី ម.១០០ ម.១២៤ថ្មី និងម.១២៧ថ្មី)

## សន្លឹកឆ្នោត

- សន្លឹកឆ្នោត (ម.៨៨ថ្មី ម.៩១ថ្មី និងម.១០២)
- ការរាប់សន្លឹកឆ្នោត (ម.១០២ ម.១០៣ ម.១០៤ ម.១០៥ថ្មី ម.១០៦ ម.១១០ ម.១១២ថ្មី ម .១១៣  និងម.១១៨ថ្មី)

## សេចក្តីសំរេចបដិសេធការចុះឈ្មោះបោះឆ្នោត

- ទម្រង់ និងបែបបទបដិសេធការចុះឈ្មោះ (ម.៥៦ថ្មី)

## ស្មៀនឃុំ សង្កាត់

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត (ម.៥៣ថ្មី ម.៥៤ថ្មី ម.៥៦ថ្មី ម.៥៧ថ្មី ម.៥៨ថ្មី ម.៥៩ថ្មី និងម.៦១ថ្មី)
- ទណ្ឌកម្ម (ម.១២២ថ្មី)

## ហិបឆ្នោត

- ម.៨៨ថ្មី ម.៨៩ ម.៩១ ម.១០៣ ម.១០៤ និងម.១៣០ថ្មី)

## អាសនៈតំណាងរាស្ត្រ

- ចំនួនអាសនៈអប្បបរមាសំរាប់រដ្ឋសភា (ម.៦)
- គណៈកម្មការកំណត់ចំនួនអាសនៈ (ម.៧)
- កាលបរិច្ឆេទផ្សព្វផ្សាយនៃការបែងចែកអាសនៈ (ម.៨)
- រូបមន្តគណនាចំនួនអាសនៈ (ម.៩)
- អាសនៈអនុគ្រោះ (ម.១០)
- រូបមន្តនៃការបែងចែកកូតាអាសនៈសរុប (ម.១១៨ថ្មី)

## អ្នកបោះឆ្នោត

- លក្ខខណ្ឌចុះឈ្មោះបោះឆ្នោត (ម.៥០ថ្មី ម.៩២ ម.៩៥ ម.១២២ថ្មី)
- របៀបចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត (ម.៤៦ថ្មី ម.៥៤ថ្មី ម.៥៦ថ្មី ម.៥៧ថ្មី ម.៥៩ថ្មី ម.៦០ថ្មី ម.៦១ថ្មី ម.៦២ថ្មី ម.៩២ថ្មី ម.៩៤ ម.៩៦ ម.៩៧ថ្មី ម.៩៨ថ្មិ ម.៩៩ ម.១០៤ ម.១០៥ថ្មី ម.១២៤ថ្មី និងម.១៣៦ថ្មិ
- សិទ្ធិទទួលបានព័ត៌មាន (ម.៧៤)
- គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ (ម.៧០)

## តំណាងគណបក្សនយោបាយ

- របស់គណបក្សនយោបាយ (ម.២៦ថ្មី ម.៦៩ថ្មី ម.៩០ ម.៩៣ ម.១០១ ម.១០២ ម.១០៣ ម.១០៦ ម.១០៨ ម.១៣០ និងម.១៣៧ថ្មី)
- ការទទួលស្គាល់ពី គ.ជ.ប (ម.២៨)

## អ្នកសង្កេតការណ៍

- របស់អង្គការមិនមែនរដ្ឋាភិបាល (ម.២៧ ម.៦៩ថ្មី ម.៩០ ម.៩៣ ម.១០២ ម.១០៣ ម.១០៨ ម.១៣០ និងម.១៣៧ថ្មី)
- ការទទួលស្គាល់ពី គ.ជ.ប (ម.២៨)

ខុមហ្វ្រែល COMFREL

# គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA


ខុមហ្វ្រែល

ទីស្នាក់ការកណ្តាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 885 745

E-mail: comfrel@online.com.kh Website: http://www.comfrel.org